■ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យរួមគ្នាប្រឆាំងព័ត៌មានក្លែងក្លាយ <ទំព័រ៖១០-១១



■ អ្នកជំនាញអង្គការសហប្រជាជាតិថា ការចាប់ខ្លួនក្លូដករអាចជាការបំពានលើច្បាប់សិទ្ធិមនុស្ស តែកម្ពុជាថាស្របនឹងច្បាប់ <ទំព័រ៖១៣

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ
# the messenger

ខែ មករា | ឆ្នាំ ២០២២ | លេខទី ១៤៧

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/ January, 2022 | #147

# រូបសំណាកព្រះនាងម៉ារីមានបុត្រច្រើន

រូបសំណាកព្រះនាងម៉ារីមានបុត្រច្រើនគឺជាឧបការីនី និងជាគំរូសម្រាប់គ្រីស្តបរិស័ទដើម្បីកសាងព្រះសហគមន៍ ដែលផ្តើមយោបល់ដោយលោកអភិបាល ទេព ច័ន្ទពិសិដ្ឋ (គីគេ) អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង កាលពីឆ្នាំ១៩៩០។ រូបសំណាកមានន័យថា «ព្រះនាងម៉ារីគឺជាមាតានៃយើងទាំងអស់គ្នា» យើងរស់នៅក្រោមអាវធំរបស់ព្រះនាងម៉ារីដោយអំណរសប្បាយដោយមានសំបុត្រអញ្ជើញចូលក្នុងព្រះសហគមន៍។ នេះបើតាមប្រសាសន៍របស់លោកអភិបាល ទេព ច័ន្ទពិសិដ្ឋ។ រូបសំណាកនេះ មានព្រះនាងម៉ារីឈរដោយគ្រងសម្លៀកបំពាក់អាវធំវែង ពរព្រះកុមារយេស៊ូដែលកំពុងលាព្រះហស្តដើម្បីទទួលមនុស្សគ្រប់គ្នាដោយទឹកមុខរីករាយ ហើយនៅគ្របអាវធំរបស់ព្រះនាងម៉ារីមានកុមារាកុមារីមួយចំនួន។ លោកអភិបាលបានបន្ថែមថា កុមារីដែលកាន់សៀវភៅតំណាងឱ្យអ្នកមានប្រាជ្ញា មានចំណេះដឹង ហើយកុមារាផ្លុំខ្លុយ គឺសំដៅអំពីការច្រៀងលើកតម្កើងព្រះជាម្ចាស់ដោយអំណសប្បាយ។ កុមារដែលនៅក្បែររទេះតំណាងឱ្យការរួបរួមសាមគ្គីគ្នាជាធ្លុងតែមួយ។ ចំណែកឯកុមារមានពិការភាពដែលជិះលើរទេះតំណាងឧបសគ្គដែលកើតមានឡើងដែលយើងជួបក្នុងសង្គមរស់នៅ ហើយរូបព្រាបសតំណាងអោយសន្តិភាព។ រូបសំណាករបស់ព្រះនាងម៉ារីដែលមានបុត្រច្រើននេះ ត្រូវបានដាក់នៅតាមព្រះសហគមន៍នានាក្នុងភូមិភាគបាត់ដំបង ដើម្បីរំលឹកដល់គ្រីស្តបរិស័ទឱ្យយកចិត្តទុកដាក់កសាងសង្គមមួយដោយសេចក្តីស្រឡាញ់ សុភាពរាបសារដូចព្រះនាងម៉ារីដែលជាមាតាព្រះយេស៊ូ និងជាគំរូសម្រាប់យើងរាល់គ្នា៕

*ដោយ៖ CSCBB*



# សេចក្តីស្រឡាញ់ជំរុញយើងឲ្យទទួល ឲ្យចេះបើកចិត្តទូលំទូលាយ ទ្រាំទ្រ និងអត់ធ្មត់



ក្នុងឆ្នាំ២០២១ កន្លងទៅ យើងម្នាក់ៗបានឆ្លងកាត់រឿងរ៉ាវជាច្រើន ទាំងអរសប្បាយ និងទុក្ខព្រួយ ខ្លោចផ្សារ ដោយសារមេរោគឆ្លងកូវីដ-១៩ ។ បទពិសោធនាំឱ្យម្នាក់រៀននូវបរិបទថ្មី ក្នុងរបៀបរស់នៅប្រចាំថ្ងៃរបស់យើង រៀនរស់ក្នុងសភាពការណ៍ដែលមានជំងឺឆ្លងដ៏សាហាវមួយនេះ រៀនរស់ក្នុងគន្លងថ្មី ដើម្បីបន្តជីវិតទៅមុខ។

មានបងប្អូនមួយចំនួនបានជួបដោយផ្ទាល់នៃការឆ្លង ជួបផ្ទាល់ដោយទទួលការសង្គ្រោះបន្ទាន់ និងជួបដោយផ្ទាល់នៃការបាត់បង់ញាតិសណ្តានរបស់ខ្លួន។ ជាងនេះទៅទៀតមានបងប្អូនដែលបានស៊ូទ្រាំ និងស៊ូលះបង់ការលំបាក ដើម្បីថែរក្សាមនុស្សដែលខ្លួនស្រឡាញ់ និងរស់នៅតាមទឹកចិត្តស្រឡាញ់ដោយមិនខ្លាចគ្រោះថ្នាក់ផ្ទាល់ខ្លួន។

ត្រង់នេះ ឱ្យយើងនឹកដល់លិខិតរបស់លោកប៉ូលថា អ្នកមានចិត្តស្រឡាញ់ មិនប្រព្រឹត្តអំពើថោកទាប មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន មិនមួម៉ៅ មិនចងគំនុំ មិនអបអរនឹងអំពើទុច្ចរិតទេ តែរីករាយនឹងសេចក្តីពិតវិញ។ អ្នកមានចិត្តស្រឡាញ់អត់ឱនឱ្យទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់។

ម្យ៉ាងទៀតសេចក្តីស្រឡាញ់ ដែលមានប្រភពពីព្រះជាម្ចាស់ បានជំរុញយើងកាន់តែខ្លាំង ឱ្យចេះមើលឃើញ យ៉ាងពិតប្រាកដពីវត្តមានរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត នៅក្នុងបងប្អូនឯទៀត ក្នុងបងប្អូនដែលងាយរងគ្រោះ និងក្នុងបងប្អូនដែលគេបោះបង់ចោលឱ្យនៅក្រៅសង្គម។ យើងមានឧទាហរណ៍ជាក់ស្តែងអំពីជីវិតរបស់អ្នកម្តាយតេរេសា នៃក្រុងគុលគូថា ប្រទេសឥណ្ឌា។

អ្នកមានចិត្តស្រឡាញ់យ៉ាងពិប្រាកដ គឺអង្គុយចាំចាប់កំហុស និង រិះគិតដល់បងប្អូនរបស់ខ្លួនមិនចេះឈប់ឈរនោះឡើយ។ ពេលខ្លះការរិះគន់អាចជួយឱ្យមនុស្សកែប្រែ និងរកផ្លូវដើម្បីទៅមុខ និងរីកចម្រើន។ ប៉ុន្តែការិះគន់មួយចំនួន ខ្វះសេចក្តីស្រឡាញ់ ដោយចាំចាប់កំហុស នោះបណ្តាលឱ្យមានជម្លោះនិងការបែកបាក់។ ម្យ៉ាងទៀតការិះគន់ច្រើន ក៏ជាអ្វីមួយ នាំឱ្យយើងខ្វះសេចក្តីស្រឡាញ់ និងខ្វះការឈ្វេងយល់ស៊ីជម្រៅអំពីគំនិត យោបល់របស់បងប្អូនដែលយើងកំពុងរិះគន់ផងដែរ។ ចូរលើកទឹកចិត្តគ្នាទៅវិញទៅមក! គាំទ្រគ្នាទៅវិញទៅមកក្នុងសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ត។ ទទួលយកសេចក្តីពិតដែលបានកើតឡើង ក្នុងព្រឹត្តិការណ៍របស់យើងផងដែរ។

ចូរផ្ញើសេចក្តីទាំងប៉ុន្មានដែលបងប្អូនមានទៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់ ទាំងទុក្ខកង្វល់ ការព្រួយបារម្ភជ្រុល និងហួងហែងជ្រុល ច្រណែន ប្រច័ណ្ឌ គំនុំ ឈ្នានីសជាដើម។

ចូរអង្វរព្រះជាម្ចាស់ សម្រាប់គ្នាទៅវិញទៅមក ដើម្បីឱ្យទាំងអស់គ្នាចម្រើនឡើងក្នុងជំនឿ តែមួយ ព្រះវិញ្ញាណតែមួយ និងព្រះបន្ទូលតែមួយ៕

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh



# វីរកណ្ដុរដោះមីន ធ្លាប់ទទួលបានមេដាយមាស បានស្លាប់ដោយសារជរាភាព



*អត្ថបទ៖ អមរិន្ទ ដានុត*

ម៉ាហ្គាវ៉ា (Magawa) កណ្ដុរហិតមីនកម្ពុជាដំបូងគេនិងធ្លាប់ទទួលបានមេដាយមាសពីប្រទេសអង់គ្លេសបានស្លាប់នៅអាយុ៨ឆ្នាំ កាលពីដើមខែមករា ឆ្នាំ២០២២ ដោយចាស់ជរា។ កណ្ដុរហិតមីននេះ ត្រូវបានហ្វឹកហាត់ដោយក្រុមអ្នកជំនាញស្ម័គ្រចិត្តបែលហ្ស៊ិករបស់អង្គការ APOPO និងបញ្ជូនមកប្រទេសកម្ពុជានៅអាយុ ៩ ខែ ដើម្បីបន្តការហ្វឹកហ្វឺន និងបំពេញបេសកកម្មដ៏គ្រោះថ្នាក់ក្នុងការដោះមីន។

លោក ហេង រតនា អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) បានឱ្យដឹងថា វីរកណ្ដុរដោះមីន ឈ្មោះម៉ាហ្គាវ៉ា(MAGAWA) បានស្លាប់នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២២ ដោយសារចាស់ជរា។

លោកបានលើកឡើងថា ៖ «កណ្ដុរម៉ាហ្គាវ៉ាទទួលបានមេដាយមាស the Gold Medal for bravery and Saving Human Lives ពីអង្គការ PDSA នៃចក្រភពអង់គ្លេសនៅឆ្នាំ២០២០»។

លោក ហេង រតនា បានបន្ថែមថា ម៉ាហ្គាវ៉ាកើតនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៤ នៅប្រទេសTanzania និងបានមកដល់កម្ពុជានៅឆ្នាំ២០១៦ ដើម្បីបំរើការងារដោះមីន។

គំរោងបោសសំអាតមីនដោយប្រើប្រាស់សត្វកណ្ដុរជាកិច្ចសហការរវាងអង្គភាពស៊ីម៉ាក់ ជាមួយអង្គការAPOPOមកពីប្រទេសបែលហ្ស៊ិក។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់មជ្ឈមណ្ឌលសកម្មភាព កំចាត់មីនកម្ពុជា បានឱ្យដឹងថា កណ្ដុរម៉ាហ្គាវ៉ា ត្រូវបានដាក់រហ័សនាមថាវីរកណ្ដុរ ដែលបានជួយសង្គ្រោះជីវិតមនុស្សតាមរយៈគម្រោងបោសសម្អាតមីន គ្រាប់មិនទាន់ផ្ទុះ ក្នុងភាពជាដៃគូរវាងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) និងអង្គការAPOPO។

មជ្ឈមណ្ឌលសកម្មភាព កំចាត់មីនកម្ពុជា បានបន្តថា កណ្ដុរនេះបានទទួលវគ្គបណ្ដុះបណ្ដាលស្ដីពីបច្ចេកទេសបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅអង្គភាពកំចាត់មីនភូមិភាគទី៤

> កណ្ដុរម៉ាហ្គាវ៉ាទទួលបានមេដាយមាស **The Gold Medal for bravery and Saving Human Lives** ពីអង្គការ **PDSA**នៃចក្រភពអង់គ្លេសនៅឆ្នាំ ២០២០

ខេត្តសៀមរាបហើយបានឆ្លងកាត់ការធ្វើតេស្តដោះមីន ដើម្បីទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការ នៅស្រុកស្រែណូយ ខេត្តសៀមរាប ចាប់ពីខែឧសភា ឆ្នាំ២០១៦ ដល់ខែតុលា ឆ្នាំ២០១៨ ។

ប្រភពដដែលបានបន្តថា ក្រោយមក ចាប់ពីខែវិច្ឆិកា ឆ្នាំ ២០១៨ ដល់ខែមីនា ឆ្នាំ២០២១ កណ្ដុរម៉ាហ្គាវ៉ា ត្រូវបានដាក់ពង្រាយដើម្បីប្រតិបត្តិការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះនៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

ក្នុងប្រតិបត្តិការបោសសម្អាតមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ អស់រយៈពេលជាងប្រាំមួយឆ្នាំមកនេះ វីរកណ្ដុរម៉ាហ្គាវ៉ាបានរំដោះផ្ទៃដីបានចំនួន 225,782



ម៉ែត្រការ៉េ ដោយបានរកឃើញគ្រាប់មីនចំនួន ៧១ គ្រាប់ និងយុទ្ធភណ្ឌមិនទាន់ផ្ទុះចំនួន ៣៨ គ្រាប់។

មជ្ឈមណ្ឌលសកម្មភាព កំចាត់មីនកម្ពុជា បានលើកឡើងទៀតថា ដោយមើលឃើញលើវីរភាព និងសមិទ្ធិផលឆ្នើមក្នុងការបោសសម្អាតមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ បានជាច្រើននេះ កណ្ដុរម៉ាហ្គាវ៉ាត្រូវបានជ្រើសរើសក្នុងការទទួលបានមេដាយមាសសម្រាប់ភាពក្លាហាន និងការសង្គ្រោះជីវិតមនុស្សកាលពីខែកញ្ញា ឆ្នាំ ២០២០ ពីមន្ទីរពេទ្យអង្គការ PDSA នៅចក្រភពអង់គ្លេស។

វីរកណ្ដុរម៉ាហ្គាវ៉ា បានចូលនិវត្តន៍ពីវិស័យសកម្មភាពមីនក្នុងខែមិថុនា ឆ្នាំ ២០២១ នៅអាយុ ៦ ឆ្នាំ ៧ ខែ។

ជាមួយគ្នានេះដែរ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន (CMAA) ក៏បានលើកឡើងពីកណ្ដុរម៉ាហ្គាវ៉ានេះផងដែរ ដោយកណ្ដុរនេះបានចំណាយពេលស្ទើរតែពេញមួយជីវិតរបស់គាត់ដើម្បីហិតស្វែងរកមីននៅកម្ពុជា និងដែលត្រូវបានទទួលស្គាល់ចំពោះការរួមចំណែករបស់គាត់ក្នុងការសង្គ្រោះជីវិតប្រជាជនកម្ពុជា។

កណ្ដុរហិតមីន ដែលធ្លាប់ទទួលបានមេដាយមាស ពីប្រទេសអង់គ្លេស មួយនេះ ត្រូវបានដាក់អោយចូលនិវត្តន៍ កាលពីខែមិថុនា ឆ្នាំ២០២១ កន្លងទៅ បន្ទាប់ពីបានបំពេញបេសកកម្មដោះមីននៅក្នុងខេត្តសៀមរាប និងខេត្តព្រះវិហារ អស់រយៈកាលជាង ៥ឆ្នាំកន្លងមក។

កណ្ដុរហិតមីន ម៉ាហ្គាវ៉ា ក៏ត្រូវបានសៀវភៅកំណត់ត្រា Guinness World Records បានដាក់បញ្ចូលក្លាយជាម្ចាស់កំណត់ត្រាកណ្ដុរដែលរកឃើញគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះច្រើនជាងគេបំផុត (The Most Landmines Detected by A Rat) ផងដែរ៕





# ក្រសួងអប់រំនៅតែបន្តធ្វើកំណែទម្រង់ ដើម្បីជួយអភិវឌ្ឍន៍ធនធានមនុស្ស ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល



*អត្ថបទ៖ អមរិទ្ធិ ដានុត*

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លោក ហង់ជួន ណារ៉ុន បានលើកឡើងថា ទិសដៅរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺត្រូវបន្តការកំណែទម្រង់ ការប្រើប្រាស់បច្ចេកវិទ្យាជាពិសេសនៅក្នុងបរិបទកូវីដ១នេះ។

លោកបានថ្លែងយ៉ាងដូចនេះក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សា២០២១-២០២២ នាខេត្តសៀមរាប កាលពីដើមខែមករា ឆ្នាំ២០២២ កន្លងមក ដោយលោកបានបញ្ជាក់ថា ក្រសួងនៅតែបន្តប្រើប្រាស់បច្ចេកវិទ្យាដើម្បីជួយគាំទ្រដល់សិស្សានុសិស្ស ហើយនិងបង្កើតនូវធនធានសិក្សាថ្មីៗបន្ថែមទៀត។



លោក ហង់ជួន ណារ៉ុន មានប្រសាសន៍ថា៖ «ការធ្វើបែបនេះ ដើម្បីឱ្យសិស្សមានសមត្ថភាព និងគុណភាព ក្លាយជាពលរដ្ឋល្អ និងអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម»។

រដ្ឋមន្ត្រីរូបនេះបានបញ្ជាក់ថា សារសំខាន់សម្រាប់បើកបវេសនកាលឆ្នាំនេះ គឺការពង្រីកវិសាលភាពកំណែទំរង់នៅតាមសាលារៀនដើម្បីឱ្យសាលារៀនទទួលបាននូវស្តង់ដារមួយមួយដែលមានប្រសិទ្ធភាពសាលារៀនដែលអាចគាំទ្រដល់សិស្ស។

លោកបន្តថា សាលារៀនដែលជួយអភិវឌ្ឍនូវធនធានមនុស្សរបស់កម្ពុជា ដើម្បីអភិវឌ្ឍកម្ពុជាឱ្យក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងក្លាយជាប្រទេសអភិវឌ្ឍតាមចក្ខុវិស័យរបស់លោកនាយករដ្ឋមន្ត្រី។

ជាមួយគ្នានេះដែរ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ណែនាំទៅដល់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបន្តដឹកនាំនិងអនុវត្តនូវទស្សនាទានថ្មី «គន្លងប្រក្រតីភាពថ្មីក្នុងវិស័យអប់រំ» ដោយគិតគូរអំពីជម្រើសនិងអភិវឌ្ឍធនធានបង្រៀន

> សាលារៀនជួយអភិវឌ្ឍន៍នូវធនធានមនុស្សរបស់កម្ពុជា ដើម្បីអភិវឌ្ឍកម្ពុជាឱ្យក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងក្លាយជាប្រទេសអភិវឌ្ឍតាមចក្ខុវិស័យរបស់លោកនាយករដ្ឋមន្ត្រី

និងរៀនឱ្យបានច្រើន សម្បូរបែប។

លោកបានលើកឡើងថា ៖ «ក្រសួងអប់រំ និងអ្នកពាក់ព័ន្ធ ត្រូវបន្តជំរុញការអប់រំឌីជីថល និងការអប់រំពីចម្ងាយ ឱ្យទាន់សភាពការណ៍ជាតិ តំបន់ និងសកលលោក»។

លោកនាយករដ្ឋមន្ត្រី ក៏បានណែនាំទៅដល់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបន្តផ្តោតការយកចិត្តទុកដាក់លើការអប់រំឆ្លើយតបទៅនឹងទីផ្សារការងារផងដែរ ដោយអនុវត្តវិធីសាស្រ្តបង្រៀនថ្មីៗក្នុងសតវត្សទី២១និងការផ្តោតលើការអប់រំវិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដែលនឹងបណ្តុះបាននូវអ្នកជំនាញចាំបាច់ក្នុងយុគសម័យឌីជីថល និងសេដ្ឋកិច្ចឌីជីថល។

មិនតែប៉ុណ្ណោះ លោកនាយករដ្ឋមន្ត្រីក៏បានអំពាវនាវទៅដល់គ្រប់គ្រឹះស្ថានសិក្សា បន្តលើកកម្ពស់សុខភាពអនាម័យក្នុងបរិបទកូវីដ-១៩ ដោយអនុវត្តតាមអភិក្រម «៣កុំ ៣ការពារ» ជាពិសេសវិធានការឆ្លើយតបនិងចូលរួមទប់ស្កាត់ភ្លាមៗ ដើម្បីការពារកុំឱ្យមានការឆ្លងកូវីដ-១៩ នៅក្នុងគ្រឹះស្ថានសិក្សា។

រួមទាំងបង្កើនការអប់រំអំពី សុវត្ថិភាពសុខភាពសិក្សា ការរក្សាគម្លាតសុវត្ថិភាព និងសុវត្ថិភាពចំណីអាហារដល់បុគ្គលិកអប់រំ និងសិស្សានុសិស្ស ព្រមទាំងត្រូវយកចិត្តទុកដាក់ក្នុងការគាំទ្រសុខភាពផ្លូវចិត្តនិងផ្លូវកាយរបស់ សិស្សានុសិស្សដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ឬប្រយោលពីជំងឺកូវីដ-១៩ និងត្រូវ អនុញ្ញាតឱ្យពួកគេ ចូលរួមក្នុងការសម្រេចចិត្តទាំងឡាយដែលប៉ះពាល់ដល់ពួកគេ។

លោក ហ៊ុន សែន ក៏បានធ្វើការផ្តាំផ្ញើផងដែរថា៖ «លោកគ្រូ អ្នកគ្រូទាំងអស់ បន្តដើរតួជាបុគ្គលនាំមុខជាឪពុកម្តាយទី២, ជាមគ្គុទ្ទេសក៍, ជាអ្នកស្រាវជ្រាវ, ជាទីប្រឹក្សា, និងជាអ្នកច្នៃប្រឌិត ព្រមទាំងត្រូវខិតខំប្រឹងប្រែងអភិវឌ្ឍសមត្ថភាព ខ្លួនជាប្រចាំ ទាំងខាងផ្នែកចំណេះដឹង ទាំងវិធីសាស្រ្តបង្រៀន រួមទាំងការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងភាសាបរទេសផងដែរ»៕

## លទ្ធផលប្រលងបាក់ឌុបឆ្នាំ២០២១ មានបេក្ខជនធ្លាក់ច្រើនជាងឆ្នាំ២០១៩

*អត្ថបទ៖ អមរិទ្ធិ ដានុត*

បេក្ខជនចំនួន ៧២០១៦នាក់ បានប្រលងជាប់មធ្យមសិក្សាទុតិយភូមិ(បាក់ឌុប)ត្រូវជា ៦៥.៦៥% ក្នុងនោះមានបេក្ខជននិទ្ទេស A ចំនួន១ ៧៥៣ នាក់។ នេះបើតាមសេចក្តីប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា នារសៀលថ្ងៃទី១៤ខែមករា ឆ្នាំ២០២២នេះ។

ក្រសួងអប់រំ យុវជន និងកីឡាបានឱ្យដឹងថា បេក្ខជនប្រឡងជាប់មានចំនួន ៧២០១៦នាក់ ត្រូវជា ៦៥.៦៥% (បើប្រៀបធៀបនឹងឆ្នាំ២០១៩ ចំនួន ៦៨.៦២%) ក្នុងនោះបេក្ខជនដែលទទួលបាននិទ្ទេស A មានចំនួន ១៧៥៣ នាក់ (ឆ្នាំ២០១៩ មានចំនួន ៤៤៣ នាក់)។

សម្រាប់និទ្ទេស B មានចំនួន ៥ ២១៥ នាក់ ដែលឆ្នាំ២០១៩ មានចំនួន ២ ៤៣០នាក់), និទ្ទេស C មានចំនួន ១១ ៦៣៤ នាក់ ដែលឆ្នាំ២០១៩ ចំនួន ៥ ៨៤៧ នាក់, និទ្ទេស D មានចំនួន ២៣ ៤៩៩ នាក់ ដែលឆ្នាំ២០១៩ ចំនួន ១៤ ១០០ នាក់, និងនិទ្ទេស E មានចំនួន ២៩ ៩១៥ នាក់ ដែលឆ្នាំ២០១៩ ចំនួន ៥៦ ២៣២ នាក់។

ក្រសួងអប់រំ យុវជន និងកីឡា បានបន្ថែមទៀតថា បេក្ខជនគ្រប់រាជធានី ខេត្តដែលទទួលបាននិទ្ទេស A ចំនួន ១៧៥៣នាក់ ក្នុងនោះបេក្ខជនមកពីរាជធានី ភ្នំពេញ ៥៦៥នាក់, ខេត្តសៀមរាប ១៥៣ នាក់, កណ្តាល ១២៧នាក់, បាត់ដំបង ១២៣នាក់, កំពង់ចាម ១១៨ នាក់ បន្ទាយមានជ័យ ៩៩នាក់, តាកែវ ៩៩នាក់, ព្រៃវែង ៨៧ នាក់, កំពត ៧៥នាក់, ត្បូងឃ្មុំ ៥៤ នាក់, ក្រចេះ ៤៥នាក់, កំពង់ធំ ៤១ នាក់, កំពង់ស្ពឺ ៣៣ នាក់, ពោធិ៍សាត់ ២៨ នាក់, ស្វាយរៀង ២៦នាក់ កំពង់ឆ្នាំង ២២នាក់, ព្រះសីហនុ ២០នាក់, រតនគិរី ០៩នាក់, ស្ទឹងត្រែង ០៦នាក់, ប៉ៃលិន ០៦នាក់, ឧត្តរមានជ័យ ០៥ នាក់, កោះកុង ០៤ នាក់, ព្រះវិហារ ០៤ នាក់, កែប ០៣នាក់, និងខេត្តមណ្ឌលគិរី ០១ នាក់។

គួររំលឹកផងដែរថា ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៧-២៨ ខែធ្នូ ឆ្នាំ២០២១ មានបេក្ខជនសរុប ចំនួន ១១៤ ១៨៧ នាក់ ក្នុងនោះ ១០៤ ២៩៩ នាក់ ជាបេក្ខជនចំណេះទូទៅ, ៤ ៤១៧ នាក់ ជាបេក្ខជនស្ទេរិន, ៣ ៤៣៦ នាក់ ជាបេក្ខជនបំពេញវិជ្ជា និង ២០៣៥ នាក់ ជាបេក្ខជនស្ទេរិនបំពេញវិជ្ជា។

គួរបញ្ជាក់ផងដែរថា ការមធ្យមសិក្សាទុតិយភូមិ ក្នុងឆ្នាំ២០២០ មិនត្រូវបានប្រព្រឹត្តឡើងឡើយ ដោយសារការឆ្លងរាតត្បាតនៃវីរុសកូវីដ១៩ខ្លាំង ហើយត្រូវបានលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន សម្រេចឱ្យបេក្ខជនទាំងអស់ជាប់ដោយស្វ័យប្រវត្តិតែម្តង ប៉ុន្តែមិនមានការកំណត់និទ្ទេសឡើយ៕

# យុវជននិងស្ត្រីស្ថិតក្នុងចំណោមជនងាយរងគ្រោះបំផុតក្នុងការបាត់បង់ការងារនៅអាស៊ីអាគ្នេយ៍ អំឡុងការរាលដាលកូវីដ-១៩




*អត្ថបទ៖ អរិយបុត្រ*

យោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលបានចេញផ្សាយថ្មីៗកន្លងទៅនេះបានឱ្យដឹងថា យុវជននិងស្ត្រី នៅអាស៊ីអាគ្នេយ៍បានកំពុងតែធុញទ្រាន់នឹងការបាត់បង់ការងារយ៉ាងច្រើនក្នុងអំឡុងពេលនៃការរីករាលដាលរាតត្បាតនៃមេរោគកូរ៉ូណាឬកូវីដ-១៩ ។

របាយការណ៍ដែលមានចំណងជើងថា «វិបត្តិមិនដូចអ្វីផ្សេងទៀត៖ កូវីដ-១៩ និងទីផ្សារការងារនៅអាស៊ីអាគ្នេយ៍» បានរកឃើញថា មនុស្សដែលមានអាយុពី ១៥ ដល់ ២៤ ឆ្នាំ ដែលតំណាងឱ្យតិចជាង ១៥% នៃកម្លាំងការងារនៅក្នុងប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងវៀតណាម បានរាប់បញ្ចូលទាំងការបាត់បង់ការងាររហូតដល់ ៤៥% ក្រោយការកើនឡើងនៃជំងឺរាតត្បាតក្នុងឆ្នាំ ២០២០ ។

ប្រភពដដែលបានបន្តថា នៅក្នុងប្រទេសថៃ ស្ត្រីមានចំនួន ៦០ភាគរយ នៃការបាត់បង់ការងារទាំងអស់ រួមទាំង ៩០% ក្នុងវិស័យផលិតកម្មនាត្រីមាសទីពីរនៃឆ្នាំ ២០២០ ។

ជំងឺរាតត្បាតក៏បានធ្វើឱ្យមានវិសមភាពដែលកំពុងកើនឡើងរវាងកម្មករជំនាញ និងគ្មានជំនាញ ដោយធ្វើឱ្យប៉ះពាល់ដល់កម្មករដែលមានជំនាញទាប ក៏ដូចជាកម្មករជំនាញមធ្យម ដែលការងាររបស់ពួកគេប្រឈមនឹងស្វ័យប្រវត្តិកម្មឬត្រូវបានផ្លាស់ប្តូរទៅកន្លែងផ្សេង។ កម្មករក្រៅផ្លូវការ កម្មករនិយោជិតខ្លួនឯង កម្មករបណ្តោះអាសន្ន និងពលករចំណាកស្រុក គឺជាក្រុមដែលងាយរងគ្រោះបំផុត។

ថ្មីៗនេះ លោក រ៉ាមេស ស៊ូប្រាម៉ានៀន ( Ramesh Subramaniam) អគ្គនាយកធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំតំបន់អាស៊ីអាគ្នេយ៍ មានប្រសាសន៍ថា «ទោះបីជាមានការឆ្លើយតបរបស់រដ្ឋាភិបាលដែលមិនធ្លាប់មានពីមុនមកក៏ដោយក៏កូវីដ-១៩ បានលាតត្រដាងនូវគម្លាតការការពារសង្គមយ៉ាងសំខាន់ដែលទាក់ទងនឹងភាពមិនផ្លូវការខ្ពស់ និងជាប់លាប់នៅទូទាំងតំបន់»។

លោកបានបន្តថា វាក៏បានផ្តល់ឱកាសសម្រាប់ប្រទេសនានាក្នុងការដោះស្រាយគម្លាតទាំងនេះ និងពង្រីកការគ្របដណ្តប់ទៅកាន់អ្នកទទួលផលថ្មី និងក្រុមដែលមិនរាប់បញ្ចូល។

នៅពេលដែលការស្ទុះងើបឡើងវិញបានធ្វើឡើង ការផ្តោតសំខាន់នៃគោលនយោបាយសារពើពន្ធអាចផ្លាស់ប្តូរកាន់តែខ្លាំងពីការធូរស្រាលទៅជាការជំរុញ និងពីការជំរុញដល់ការវិនិយោគតាមរចនាសម្ព័ន្ធដែលនឹងជំរុញកំណើនប្រកបដោយនិរន្តរភាព។ នេះបើតាមការបញ្ជាក់ពីលោករ៉ាមេស ស៊ូប្រាម៉ានៀន។

របាយការណ៍ដដែលនេះក៏បានបង្ហាញពីរបៀបដែល មេរោគកូវីដ-១៩ បានជះឥទ្ធិពលដល់ទីផ្សារការងារនៅក្នុងប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងប្រទេសវៀតណាម ចាប់តាំងពីការចាប់ផ្តើមនៃជំងឺរាតត្បាត។ វាមានគោលបំណងជួយអ្នកបង្កើតគោលនយោបាយកំណត់អាទិភាព ឧបសគ្គ និងឱកាសសម្រាប់ការអភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រទីផ្សារការងារប្រកបដោយប្រសិទ្ធភាពក្នុងអំឡុងពេលនៃការងើបឡើងវិញនៃសេដ្ឋកិច្ច និងលើសពីនេះ។

ប្រភពដដែលបានបន្តថា តំបន់នេះរងការវាយប្រហារយ៉ាងខ្លាំងក្នុងអំឡុងត្រីមាសទីពីរនៃឆ្នាំ ២០២០ នៅពេលដែលវិធានការទប់ស្កាត់របស់រដ្ឋាភិបាលមានកម្រិតធ្ងន់ធ្ងរបំផុត។ ក្នុងអំឡុងពេលនោះ កម្មករម្នាក់ក្នុងចំណោមប្រាំនាក់ក្នុងប្រទេសហ្វីលីពីនបានបាត់បង់ការងារឬបានចាកចេញពីកម្លាំងការងារទាំងស្រុង។ ប្រហែល ៩០% នៃជនជាតិវៀតណាមបាត់បង់ការងាររបស់ពួកគេ ហើយឈប់ស្វែងរកការងារថ្មី រីឯជនជាតិឥណ្ឌូនេស៊ី មាន៦០% និងជនជាតិម៉ាឡេស៊ីមានប្រហែលជា ៤០ %។

លោកស្រី អាយ៉ាកូ អ៊ីណាហ្គាគី ( Ayako Inagaki) នាយកការអភិវឌ្ឍន៍មនុស្សនិងសង្គមប្រចាំអាស៊ីអាគ្នេយ៍ របស់ធនាគារអភិវឌ្ឍន៍អាស៊ី បានឲ្យដឹងថា ជំងឺរាតត្បាត និងហានិភ័យនៃកំណើនសេដ្ឋកិច្ចយឺត និងវិសមភាពកើនឡើងបានគូសបញ្ជាក់ពីតម្រូវការសម្រាប់គោលនយោបាយសារពើពន្ធដែលហួសពីតួនាទីប្រឆាំងវដ្តរបស់ខ្លួន តាមរយៈការកើនឡើងនៃការវិនិយោគលើការការពារសង្គម និងហេដ្ឋារចនាសម្ព័ន្ធរបស់វា។

លោកស្រីបានបញ្ជាក់ថា ៖ «ប្រទេសនានាគួរតែជំរុញការវិនិយោគលើធនធានមនុស្ស និងប្រមូលធនធានក្នុងស្រុក ដើម្បីបង្កើតកម្មវិធីគាំពារសង្គមប្រកបដោយនិរន្តរភាព និងរួមបញ្ចូល និងបង្កើនការរួមចំណែកធានារ៉ាប់រងសង្គម»។

រហូតមកដល់ពេលនេះការផលិត គឺជាប្រភពការងារដ៏ច្រើន ប៉ុន្តែដោយសារតែការរីករាលដាលនៃមេរោគ អ្នកដែលធ្វើការនៅក្នុងវិស័យនេះ ក៏ប្រឈមមុខនឹងការបាត់បង់ការងារជាច្រើនដោយនៅក្នុងនោះភាគច្រើននៅអាស៊ីអាគ្នេយ៍។ នៅក្នុងតំបន់នេះ សហគ្រាសធុនតូចខ្នាតតូច និងមធ្យមកំពុងតែ រងផលប៉ះពាល់មិនសមាមាត្រដោយការកាត់ការងារ ដោយសារពួកគេមានសាច់ប្រាក់តិច ឬលទ្ធភាពទទួលបានការគាំទ្រពីរដ្ឋាភិបាល។

ស្ត្រីដែលចូលបម្រើការងារវិញនៅដើមឆ្នាំ ២០២១ ភាគច្រើនជាអ្នកធ្វើការដោយខ្លួនឯង ឬក្នុងវិស័យក្រៅផ្លូវការ ដែលអាចប៉ះពាល់ដល់ការអភិវឌ្ឍន៍អាជីពរបស់ពួកគេក្នុងរយៈពេលយូរ។

កម្មករក្រៅផ្លូវការ ដែលជាកម្មករក្រីក្រឬស្ទើរតែក្រីក្រក្នុងតំបន់មានភាពងាយរងគ្រោះខ្លាំង ដោយសារពួកគេមានកម្រិតសន្តិសុខការងារ និងការការពារសង្គមមានកម្រិតឬមិនមាន។ ពលករចំណាកស្រុកចំនួន ១០ លាននាក់ក្នុងតំបន់នេះក៏ទទួលរងការរឹតត្បិតលើការធ្វើដំណើរ និងការចល័តផងដែរ ពីព្រោះពួកគេជារឿយៗមិនមានសន្តិសុខការងារ ឬការចូលទៅកាន់ប្រព័ន្ធសុខភាព និងសុខុមាលភាពនៅក្នុងប្រទេសម្ចាស់ផ្ទះរបស់ពួកគេ៕

# អន្ទាក់ជាង៦ម៉ឺននិងកាំភ្លើងកែច្នៃជាង៧០០គ្រឿងត្រូវបានដោះចេញពីតំបន់ការពារធម្មជាតិក្នុង ឆ្នាំ២០២១

*អត្ថបទ៖ អមរិន្ទ ដានុត*

មន្ត្រីជាន់ខ្ពស់នៃក្រសួងបរិស្ថាន បានឱ្យដឹងថា អន្ទាក់ចំនួន ៦១ ៦១១ ត្រូវដោះចេញពីតំបន់ការពារធម្មជាតិនៅឆ្នាំ ២០២១កន្លងមកនេះ និងកាំភ្លើងកែច្នៃចំនួន ៧៥៨ គ្រឿងត្រូវបានដកហូត រីឯសត្វព្រៃជាច្រើនត្រូវបានសង្គ្រោះជីវិត។

លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការនិងជាអ្នកនាំពាក្យក្រសួងបរិស្ថាន បានថ្លែងឱ្យដឹងថា ក្នុងកិច្ចខិតខំប្រឹងប្រែងការពារ អភិរក្សព្រៃឈើ និងសត្វព្រៃនៅកម្ពុជា មន្ត្រីឧទ្យានុរក្សនៃក្រសួងបរិស្ថាន រួមជាមួយអង្គការអភិរក្សជាដៃគូ និងសហគមន៍តំបន់ការពារធម្មជាតិបានដោះអន្ទាក់បានចំនួន ៦១ ៦១១ អន្ទាក់ពីក្នុងតំបន់ការពារធម្មជាតិ។

លោកបានបន្តថា ការដោះអន្ទាក់ទាំងនេះចេញ បានជួយសង្គ្រោះដល់សត្វព្រៃមិនឱ្យជាប់អន្ទាក់របស់ព្រានព្រៃ និងគ្រោះថ្នាក់ដល់មនុស្សផងដែរ។

បរិមាណអន្ទាក់ដែលបានដោះនៅឆ្នាំ ២០២១ កន្លងទៅនេះមានចំនួនកើនឡើងប្រមាណជាង ២០% បើប្រៀបធៀបនឹងបរិមាណអន្ទាក់ដោះបាននៅឆ្នាំ២០២១ ដែលមានចំនួន ៤៣ ២៧០ អន្ទាក់។

អន្ទាក់ដែលត្រូវបានដោះនោះ គឺជាឃាតករលាក់មុខសម្លាប់សត្វព្រៃ ព្រោះមានប្រភេទអន្ទាក់ឆក់ ខ្សែភ្លើង អន្ទាក់វាយបំបាក់ស្មងជើង និងប្រភេទផ្សេងៗទៀត។ នេះបើតាមការបញ្ជាក់ពីលោក នេត្រ ភក្ត្រា។

> ដើម្បីបញ្ឈប់ការបរបាញ់សត្វ បញ្ឈប់ការដាក់អន្ទាក់ចាប់សត្វ សូមប្រជាពលរដ្ឋកុំបរិភោគសាច់សត្វ កុំជួញដូរសត្វព្រៃនិងកុំជឿលើជំនឿថាបរិភោគសាច់សត្វឈាម ឬយកឆ្អឹងសត្វព្រៃជាឱសថប៉ូវកម្លាំងឬជំនួយដល់សុខភាព តែវានឹងធ្វើប្រឈមមុខនឹងគ្រោះថ្នាក់ ដោយសារតែអាចមានមេរោគផ្សេង














លោកបានថ្លែងថា ៖ «អន្ទាក់នៅតែជាការគំរាមកំហែងយ៉ាងខ្លាំងដល់សត្វព្រៃគ្រប់ប្រភេទជាពិសេសសត្វជើងចំពាម ហើយមិនមែនត្រឹមតែកម្ពុជាទេដែលមានបញ្ហាប្រឈមនឹងវត្តមានអន្ទាក់នៅក្នុងតំបន់ការពារធម្មជាតិ តែតំបន់អភិរក្សនៅតាមបណ្តាប្រទេសនានាក្នុងទ្វីបអាស៊ីក៏ទទួលរងនូវការគំរាមកំហែង ដោយសារអន្ទាក់ដែរ»។

អន្ទាក់ជាច្រើនលានត្រូវបានគេដឹងថាបានដាក់នៅក្នុងតំបន់អភិរក្សក្នុងប្រទេសវៀតណាម កម្ពុជា ឡាវ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី។

លោក នេត្រ ភក្ត្រា បានលើកឡើងថា ៖ «កត្តាដែលគំរាមកំហែងខ្លាំងចំពោះសត្វព្រៃ គឺអន្ទាក់ដែលជាឃាតករលាក់មុខ។ ដោយសារតែសម្ភារសម្រាប់ធ្វើអន្ទាក់មានលក់នៅលើទីផ្សារ និងមានតម្លៃថោក»។

ចំនួនអន្ទាក់ត្រូវបានប៉ាន់ស្មានថា មានការកើនឡើង ហើយនៅអាស៊ីមានអន្ទាក់ ប្រមាណ ជាង ១២លានអន្ទាក់ត្រូវបានលួចដាក់ក្នុងតំបន់ការពារនៅទូទាំងតំបន់អាស៊ី។

មន្ត្រីឧទ្យានុរក្សមិនត្រឹមតែចុះល្បាត ដើម្បីទប់ស្កាត់ បទល្មើសបំផ្លាញធនធានធម្មជាតិ ការកាប់បំផ្លាញព្រៃឈើប៉ុណ្ណោះទេ ប៉ុន្តែមន្ត្រីឧទ្យានុរក្សក៏បានដើរស្វែងរកអន្ទាក់ និងដោះចេញព្រមទាំងបំផ្លាញអន្ទាក់ចោលដើម្បីសង្គ្រោះជីវិតសត្វព្រៃផងដែរ។

ទន្ទឹមនឹងនោះដែរ បើតាមលោក នេត្រ ភក្ត្រា ក្រៅពីអន្ទាក់ដែលបានបង្កគ្រោះថ្នាក់សម្លាប់សត្វព្រៃ មន្ត្រីឧទ្យានុរក្សក៏បានដកហូតកាំភ្លើងកែច្នៃប្រើប្រាស់ សម្រាប់ការប្រមាញ់សត្វព្រៃចំនួន ៧៥៨ ដើមត្រូវបានដកហូតនៅឆ្នាំ ២០២១ ។

លោក នេត្រ ភក្ត្រា បានគូសបញ្ជាក់ថា ៖ «បរិមាណនេះប្រហាក់ប្រហែលឆ្នាំ ២០២០ ដែរ។ ការកើនឡើងនៃកាំភ្លើងកែច្នៃក៏ជាផ្នែកមួយគំរាមកំហែងដល់សត្វព្រៃ ហើយកាំភ្លើងកែច្នៃនេះ គឺជាអាវុធដែលគ្រោះថ្នាក់បំផុតផងដែរ»។

លើសពីនេះ សត្វឆ្កែប្រដេញ ក៏ជាមូលហេតុនាំឱ្យប៉ះពាល់ដល់សត្វព្រៃដែរ។ ប្រជាជនមួយចំនួនបានចិញ្ចឹមសត្វឆ្កែប្រដេញជាហ្វូង ដើម្បីបណ្តើរចេញទៅប្រមាញ់សត្វព្រៃ ដែលជាកត្តារួមផ្សំធ្វើឱ្យចំនួនសត្វព្រៃត្រូវបានថយចុះដោយការប្រមាញ់ និងស្លាប់ដោយសារតែជំងឺឆ្លងពីឆ្កែស្រុក។

«ដើម្បីបញ្ឈប់ការបរបាញ់សត្វ បញ្ឈប់ការដាក់អន្ទាក់ចាប់សត្វ សូមប្រជាពលរដ្ឋកុំបរិភោគសាច់សត្វ កុំជួញដូរសត្វព្រៃ និងកុំជឿលើជំនឿថាបរិភោគសាច់សត្វ ឈាម ឬយកឆ្អឹងសត្វព្រៃជាឱសថប៉ូវកម្លាំងឬជំនួយដល់សុខភាព តែវានឹងធ្វើប្រឈមមុខនឹងគ្រោះថ្នាក់ ដោយសារតែអាចមានមេរោគផ្សេង»។ លោក នេត្រ ភក្ត្រា បញ្ជាក់៕




# TI ថា អំពើពុករលួយប្រចាំឆ្នាំ២០២១ កើនបាន២ពិន្ទុ តែរាជរដ្ឋាភិបាលកម្ពុជាមិនឲ្យតម្លៃក្នុងចំណាត់ថ្នាក់នេះឡើយ

*អត្ថបទ៖ អមរិន្ទ ដានុត*

លទ្ធផលសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយឆ្នាំ ២០២១ បានបង្ហាញថា កម្ពុជាទទួលបានពិន្ទុ ២៣ ដែលកើនឡើងចំនួនពីរពិន្ទុបើធៀបនឹងឆ្នាំ២០២០ និងឈរនៅចំណាត់ថ្នាក់ទី១៥៧ ក្នុងសកលលោក។ នេះបើយោងតាម របាយការណ៍ដែលបានចេញផ្សាយដោយអង្គការតម្លាភាពអន្តរជាតិ (TI) ដែលមានការិយាល័យនៅទីក្រុងប៊ែរឡាំងប្រទេសអាល្លឺម៉ង់ កាលពីថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២២ ។

សេចក្តីថ្លែងការណ៍ព័ត៌មានរបស់ អង្គការតម្លាភាពអន្តរជាតិ បានលើកឡើងថា កម្ពុជាទទួលបានពិន្ទុ ២៣ ដែលកើនឡើងចំនួនពីរពិន្ទុបើធៀបនឹងឆ្នាំមុនដែលទទួលបាន២១ពិន្ទុ ហើយឈរនៅចំណាត់ថ្នាក់ទី១៥៧ ក្នុងសកលលោក។

អង្គការតម្លាភាពអន្តរជាតិ (TI) បានឱ្យដឹងថា ៖ «ខណៈដែលពិន្ទុឆ្នាំនេះអាចត្រូវបានមើលឃើញថា ជាសញ្ញាណវិជ្ជមាន ប៉ុន្តែពិន្ទុនេះនៅតែមានកម្រិតទាប ដែលបង្ហាញថា កម្ពុជាបន្តបោះជំហានយ៉ាងយឺតពីក្រោយបណ្តាប្រទេសក្នុងតំបន់ ក៏ដូចជាពិភពលោក»។

នៅក្នុងសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយប្រចាំឆ្នាំ ២០២១ កម្ពុជាទទួលបានពិន្ទុ ២៣ លើពិន្ទុអតិបរមា ១០០ គឺឡើងពីពិន្ទុ ២១ ដែលទទួលបានក្នុងឆ្នាំ២០២០ ។ ជាមួយនឹងពិន្ទុនេះ កម្ពុជាជាប់ចំណាត់ថ្នាក់ទី ១៥៧ ក្នុងចំណោម ១៨០ ប្រទេស និងដែនដីដែលត្រូវបានដាក់បញ្ចូលក្នុងការសិក្សា។

TI បានបន្តថា នៅកម្រិតតំបន់ ប្រទេសកម្ពុជាបន្តស្ថិតក្នុងចំណោមប្រទេសមានពិន្ទុទាបជាងគេទី៣ នៅតំបន់អាស៊ីប៉ាស៊ីហ្វិច នៅលើតែប្រទេសអាហ្វហ្គានីស្ថាន និងកូរ៉េខាងជើងតែប៉ុណ្ណោះ ហើយក៏ជាប្រទេសមានពិន្ទុទាបជាងគេបំផុតក្នុងតំបន់អាស៊ានផងដែរ។ លទ្ធផលពិន្ទុCPIរបស់ប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ានគឺមានភាពចម្រុះ។

លោក ប៉ិច ពិសី នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា បានលើកឡើងថា អង្គការតម្លាភាពកម្ពុជាសាទរចំពោះកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់រដ្ឋាភិបាលក្នុងកិច្ចគាំពារសុខភាពសាធារណៈ ការកាត់បន្ថយផលប៉ះពាល់សង្គម និងសេដ្ឋកិច្ចពីវិបត្តិជំងឺកូវីដ-១៩ និងការធ្វើឲ្យប្រសើរនូវសេវាសាធារណៈតាមរយៈការកាត់បន្ថយ



អំពើពុករលួយខ្នាតតូច។

លោកបានថ្លែងថា ៖ «យ៉ាងណាក៏ដោយ ពិន្ទុCPI របស់កម្ពុជានៅមានកម្រិតទាបនេះ បង្ហាញជារួមថា អភិបាលកិច្ច ជាពិសេសស្ថាប័នសាធារណៈនៅតែបន្តរងការប៉ះពាល់យ៉ាងខ្លាំង ខណៈដែលអំពើពុករលួយទ្រង់ទ្រាយធំនៅតែជាឧបសគ្គធំបំផុត។ ឆន្ទៈនយោបាយកាន់តែខ្លាំង និងកិច្ចខិតខំប្រឹងប្រែងកាន់តែមុះមុត គឺចាំបាច់ខ្លាំងណាស់ ដើម្បីធ្វើឱ្យស្ថានភាពនេះមានភាពប្រសើរឡើង»។

ជាមួយគ្នានេះដែរ អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា លោក ផៃ ស៊ីផាន ថាការដាក់ពិន្ទុ និងចំណាត់ថ្នាក់នេះមិនបានឆ្លុះបញ្ចាំងពីតថភាព និងការខិតខំប្រែងរបស់រដ្ឋាភិបាលកម្ពុជាឡើយ ហើយលោកមិនដឹងឱ្យតម្លៃរបាយការណ៍យ៉ាងណានោះដែរ។

លោកបានថ្លែងនាព្រឹកថ្ងៃទី២៧ ខែមករា ថា រាជរដ្ឋាភិបាលកម្ពុជាក៏មិនខ្វល់ចំពោះការដាក់ចំណាត់ថ្នាក់អំពើពុករលួយនៅកម្ពុជាដែលមានស្ថានភាពអាក្រក់ជាងបណ្តាប្រទេសជិតខាងឡើយ ដោយសារវាផ្ទុយពីអ្វីដែលជាការពិតនៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ននេះ។

លោកមានប្រសាសន៍ថា ៖ «សកម្មភាពរបស់អង្គការតម្លាភាពកម្ពុជា ដែលជាអង្គការក្រៅរាជរដ្ឋាភិបាល គ្រាន់តែជាអាយ៉ងរបស់បរទេសប៉ុណ្ណោះ ខណៈការដាក់ចំណាត់ថ្នាក់នេះ ក៏មិនបង្ហាញអំពីនីតិវិធីច្បាស់លាស់ជាសាធារណៈដើម្បីឲ្យមហាជនបានដឹងលឺនោះទេ»។

លោក ផៃ ស៊ីផាន បានបន្ថែមថា កម្ពុជាមិនមែនត្រឹមតែមានឆន្ទៈក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយនោះទេ តែកម្ពុជាមានកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ និងបានអនុវត្តតាមវិន័យយ៉ាងត្រឹមត្រូវថែមទៀតផងដែរ៕



# បន្លែនិងម្ទេស
## មានទីផ្សារនៅក្រៅប្រទេស
## ប៉ុន្តែបរិមាណនៅតិចតួចនៅឡើយ





*អត្ថបទ៖ អរិយបុត្រ*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអះអាងថា ផលិតផលបន្លែមួយចំនួន និងម្ទេសកម្ពុជា មានទីផ្សារនៅក្រៅប្រទេស ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏បរិមាណនៃការនាំចេញ គឺនៅមានចំនួនតិចតួចនៅឡើយ ហើយទីផ្សារក៏នៅចង្អៀតផងដែរ។

ប្រភពដដែលបានឲ្យដឹងថា នៅក្នុងឆ្នាំ២០២១ កន្លងទៅ បន្លែចម្រុះមានចំនួនប្រមាណជា ១០៤,២៥តោន ត្រូវបាននាំចេញទៅប្រទេសបារាំង គ្រាន់តែបរិមាណនេះថយចុះចំនួន ១,១៥% ដោយឡែកម្ទេស មានការនាំចេញទៅកាន់ប្រទេសចំនួន៥ផងដែរ ទាំងស្រស់និងក្រៀម គ្រាន់តែក្រៀមមានទីផ្សារទូលាយជាង។

ការនាំចេញម្ទេសស្រស់របស់កម្ពុជាក្នុងឆ្នាំ ២០២១ កន្លងទៅនេះ មានបរិមាណជិត ១០ម៉ឺនតោន ដែលមានការកើនឡើងជិត៤០% ដែលក្នុងនោះទៅកាន់ប្រទេសថៃមានចំនួន ជាង ៩ម៉ឺន៨ពាន់ តោន និងប្រទេសអារ៉ាប់រួម មានចំនួនតែ ០,០០២ តោន ប៉ុណ្ណោះ។

ចំណែកម្ទេសក្រៀម កម្ពុជាបាននាំចេញនៅក្នុងបរិមាណសរុប ចំនួនជាង២ពាន់តោន ដែលមានការកើនឡើងចំនួន២០% ដែលមានការនាំចេញទៅប្រទេសថៃចំនួន ២ ១៦០ តោន ប្រទេសប៊ែលហ្ស៊ិក ចំនួន ០,២១ តោន ប្រទេសកូរ៉េ ចំនួន ០,០១ តោន និងប្រទេសកាណាដា ចំនួន ០,០១ តោន។

ពាក់ព័ន្ធទៅនឹងការជំរុញផលិតផលកសិកម្មនេះ លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅតែបន្តជំរុញឲ្យកសិករកម្ពុជា ខិតខំបង្កបង្កើនផលបន្ថែមទៀត ដើម្បីនាំចេញនិងជំរុញកាត់បន្ថយបរិមាណបន្លែនាំចូលមកក្នុងប្រទេស។

លោកបានថ្លែងឱ្យដឹងបន្ថែមទៀតថា៖ «មកដល់ពេលនេះកម្ពុជា ជាពិសេសក្រសួងកំពុងតែធ្វើការជាមួយនឹងកសិករ តាមរយៈគម្រោងជាច្រើនដែលក្រសួងដាក់ចេញ ដើម្បីសំដៅជំរុញពង្រីកទីផ្សារ បង្កើនការយល់ដឹងអំពីទីផ្សារ បំពាក់បច្ចេកទេស និងជំនាញកសិកម្មថ្មីៗ និងជំរុញទីផ្សារអ្នកជំនាញកសិកម្មទៅក្រេបជញ្ជក់បច្ចេកវិទ្យាកសិកម្មពីបរទេស»៕

# រដ្ឋមន្ត្រីក្រសួងកសិកម្មអះអាងថាផលិតកម្មកសិកម្មកម្ពុជាមានតម្លៃប្រមាណជា ១៨ពាន់លានដុល្លារ

"នៅឆ្នាំ២០២១ កន្លងទៅនេះ កម្ពុជាសម្រេចបាន តម្លៃផលិតកម្មសត្វសរុបមានទំហំ ៥ ១០០ លានដុល្លារអាមេរិក មានកំណើន ៦% ធៀបនឹងឆ្នាំ២០២០ ដែលទទួលបាន ៤ ៨១៣ លានដុល្លារអាមេរិក"






*អត្ថបទ៖ អរិយបុត្រ*

លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអះអាងថា ផលិតកម្មកសិកម្មកម្ពុជាទាំងដំណាំ បសុសត្វ កៅស៊ូ អនុផលព្រៃឈើ ក៏ដូចជាជលផល មានតម្លៃសរុបលើសពី ១៨ ពាន់លានដុល្លារនៅក្នុង ឆ្នាំ២០២១ កន្លងទៅនេះ។

លោកបានអះអាងថា នៅឆ្នាំ ២០២១ កន្លងទៅនេះ ផលិតកម្មដំណាំកសិកម្មនៅទូទាំងប្រទេសទទួលបានសរុបចំនួន ជិង៣៦លាន តោន ដែលកើនឡើង ២៣% ធៀបនឹងឆ្នាំ២០២០ រីឯតម្លៃផលិតផលសរុបនៃផលិតកម្មដំណាំមានទំហំ ១០ ៥៦៧លាន ដុល្លារអាមេរិក កើនលើសឆ្នាំ ២០២០ចំនួន ៣៣,១៥%។

ដំណាំស្រូវ មានចំនួនជាង១២លាន តោន កើនឡើងជាង ១១% ធៀបនឹងឆ្នាំ២០២០ ដែលមានបរិមាណចំនួនជិត ១១លាន តោន, ដំណាំសាកវប្បកម្ម មានចំនួនជាង ៤លាន តោន។ ប្រភេទដំណាំសំខាន់ៗមានដូចជា ដំណាំបន្លែគ្រប់ប្រភេទ ចំនួន ជាង៩សែន តោន ដំណាំហូបផ្លែ ចំនួនជាង ៣លានតោន និង រុក្ខជាតិលម្អ មានចំនួន ៩០តោន។

ដោយឡែកសម្រាប់ដំណាំឧស្សាហកម្ម មានចំនួនជា ១៩លាន តោន ដែលប្រភេទដំណាំសំខាន់ៗដូចជាដំណាំដំឡូងមី ដំណាំពោតក្រហម ដំណាំអំពៅ គ្រាប់ស្វាយចន្ទី ដូង និង ដំណាំឧស្សាហកម្មផ្សេងៗមួយចំនួនទៀត។

លោក វេង សាខុន បានបន្តថា ការប៉ាន់ស្មានតម្លៃជាទឹកប្រាក់ទទួលបានពីផលិតកម្មដំណាំកសិកម្ម ឆ្នាំ២០២១ សរុបមានចំនួនប្រមាណ ១០ ៥៦៧ លានដុល្លារអាមេរិក កើនលើសឆ្នាំ២០២០ចំនួន ៣៣,១៥%។ តម្លៃទទួលបានពីការនាំចេញកសិផលមានវិញ្ញាបនបត្រ មានចំនួន ជិត៤ លានដុល្លារអាមេរិក កើនលើសឆ្នាំ២០២០ចំនួន ១០៥,៤៣%។

សម្រាប់តម្លៃទទួលបានពីការនាំចេញកសិផលគ្មានវិញ្ញាបនបត្រ មានចំនួន ៩៥៩ លានដុល្លារអាមេរិកដែលមានការថយចុះចំនួន ៣៦,២៩% ធៀបឆ្នាំ២០២០ ហើយតម្លៃទទួលបានពីកសិផលដែលសល់សម្រាប់ប្រើប្រាស់ក្នុងស្រុក មានចំនួន ៥ ៦៤៨ លានដុល្លារអាមេរិក កើនលើសឆ្នាំ២០២០ចំនួន ២៥,៤៥%។

ទាំងនេះគឺជាគុណតម្លៃនៃវិស័យដំណាំកសិកម្ម ដោយឡែកលោករដ្ឋមន្ត្រីបានបន្ថែមថា តម្លៃផលិតកម្មសត្វនៅកម្ពុជាក៏មានទំហំរហូតដល់ទៅ ៥ ១០០ លានដុល្លារបន្ថែមទៀត។

លោកបានថ្លែងថា៖«នៅឆ្នាំ២០២១ កន្លងទៅនេះ កម្ពុជាសម្រេចបាន តម្លៃផលិតកម្មសត្វសរុបមានទំហំ ៥ ១០០ លានដុល្លារអាមេរិក មានកំណើន ៦% ធៀបនឹងឆ្នាំ២០២០ ដែលទទួលបាន ៤ ៨១៣ លានដុល្លារអាមេរិក»។

លោកបានបន្ថែមថា តម្លៃផលិតកម្មសត្វនៅក្នុងស្តុកនៅទូទាំងប្រទេសទទួលសម្រេចបានចំនួន ៣ ១៥០ លានដុល្លារអាមេរិក មានកំណើនចំនួន ៧,៤% ធៀបនឹងឆ្នាំ២០២០ ដែលទទួលបាន ២ ៩៣៤ លានដុល្លារអាមេរិក រីឯតម្លៃផលិតកម្មសត្វផ្គត់ផ្គង់ក្នុងស្រុកនៅទូទាំងប្រទេសសម្រេចបានចំនួន ១ ៨៨៤ លានដុល្លារអាមេរិក មានកំណើន ២,៨% ធៀបនឹងឆ្នាំ២០២០ ដែលទទួលបាន ១ ៨៣១ លានដុល្លារអាមេរិក ។

លោក វេង សាខុន បានបន្តថា តម្លៃផលិតផលសត្វនាំចេញ សត្វរស់, សាច់, ស្បែកជាដើម សម្រេចបានចំនួន ៦៦,១៣ លាន ដុល្លារអាមេរិក មានកំណើន ៤០,១% ធៀបនឹងឆ្នាំ២០២០ ដែលទទួលបាន ៤៧,១៨ លាន ដុល្លារអាមេរិក៕

# លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យអ្នកសារព័ត៌មានទាំងអស់ រួមគ្នាប្រឆាំងព័ត៌មានក្លែងក្លាយ ខណៈស្ថាប័នសារព័ត៌មានមានការគាំទ្រ

*អត្ថបទ៖ អមរិទ្ធ ជានុត*

ខណៈដែលមានការផ្សព្វផ្សាយសារ និងវីដេអូពាក់ព័ន្ធនឹងដំណឹងក្លែងក្លាយ ព័ត៌មានមិនពិត ការញុះញង់ និងបំពុលសង្គមមានការកើនឡើង ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានអំពាវនាវដល់អ្នកសារព័ត៌មានទាំងអស់ ត្រូវចូលរួមប្រឆាំងជាមួយនឹងព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយទាំងនៅក្របខ័ណ្ឌជាតិ និងអន្តរជាតិ។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងថា ជាមួយវឌ្ឍនភាពនិងជោគជ័យដែលកម្ពុជាសម្រេចបាននាពេលកន្លងមក ក៏មានកិច្ចការជាច្រើនទៀតដែលស្ថាប័នព័ត៌មានត្រូវចូលរួមបំពេញនាពេលខាងមុខដូចជា ការរៀបចំកិច្ចប្រជុំកំពូលអាស៊ានឆ្នាំ ២០២២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

កម្ពុជាក៏មានការរៀបចំប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣ ដែលទាំងនេះសុទ្ធតែជាព្រឹត្តិការណ៍សំខាន់ៗ និងជាប្រវត្តិសាស្ត្រសម្រាប់កម្ពុជា ដែលអ្នកសារព័ត៌មាន ទាំងអស់ត្រូវត្រៀមលក្ខណៈចូលរួមផ្សព្វផ្សាយទៅកាន់សកលលោកបង្ហាញអំពីការវិវត្តរបស់កម្ពុជា។

ជាមួយគ្នានេះដែរ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានឱ្យស្ថាប័នព័ត៌មាន ក៏ដូចជាអ្នកសារព័ត៌មានត្រូវបង្កើនភាពជាដៃគូជាមួយរាជរដ្ឋាភិបាល ដោយត្រូវបំពេញតួនាទីជាស្ពានចម្លងផ្សារភ្ជាប់ទំនាក់ទំនងពីស្ថាប័នរដ្ឋទៅប្រជាជន និងពីប្រជាជនមកស្ថាប័នរដ្ឋវិញទាំង។

លោកបានលើកឡើងតាមរយៈសារលិខិតក្នុងឱកាសទិវានៃពិធីជំនួបរវាងប្រមុខរាជរដ្ឋាភិបាលកម្ពុជា ជាមួយអ្នកសារព័ត៌មានកម្ពុជា លើកទី៦ថា សារព័ត៌មានត្រូវបន្តចូលរួមប្រយុទ្ធជាមួយភាពអសកម្ម ភាពមិនប្រក្រតី អំពើពុករលួយ និងភាពអយុត្តិធម៌ នៅក្នុងសង្គមដើម្បីកសាងកម្ពុជា ជាសង្គមមួយដែលស្អាតស្អំ មានតម្លាភាព។

លោកបានបញ្ជាក់ថា៖ «សុំឱ្យអ្នកសារព័ត៌មានរបស់យើងចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងពេលដែលរាជរដ្ឋាភិបាលកំពុងជម្រុញកំណែទម្រង់រដ្ឋ ដើម្បីឱ្យមានតម្លាភាពដែលទាមទារឱ្យអ្នកសារព័ត៌មានបំពេញតួនាទីតាមវិជ្ជាជីវៈ មានសមត្ថភាព និងសិក្សាបញ្ហាដល់ ទីជម្រៅ»។

លោក ហ៊ុន សែន បានបន្តថា៖ «ត្រូវហ៊ានបញ្ចេញនូវព័ត៌មានពិត មិនក្លែងបន្លំ បំភ្លៃការពិត និងត្រូវបន្តបំផ្លាញចោលពួកឱកាសនិយមស្វែងយកផលប្រយោជន៍ផ្ទាល់ខ្លួនជ្រកក្រោមស្លាកសារព័ត៌មានធ្វើឱ្យប៉ះពាល់ដល់តម្លៃកិត្យានុភាពរបស់ អ្នកសារព័ត៌មានទូទៅនិងស្ថាប័នសារព័ត៌មាន»។

> **វិជ្ជាជីវៈនីមួយៗ ដែលទទួលបានការគោរព ការជឿទុកចិត្តពីសាធារណៈជន គឺអាស្រ័យក្រមសីលធម៌នេះឯង មុនគេបំផុត។ បើសីលធម៌ធ្លាក់ចុះ គឺអ្វីៗ នឹងធ្លាក់ចុះទៅតាមគ្នា។ នៅពេលបាត់បង់នូវជំនឿទុកចិត្តនិងការគោរព គឺប្រែថា ស្លាប់**

ការចូលរួមប្រយុទ្ធប្រឆាំងព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយទាំងនៅក្របខ័ណ្ឌជាតិ និងអន្តរជាតិ ដែលបច្ចុប្បន្នតំណាងសារព័ត៌មានកម្ពុជាក៏មាននៅក្នុងក្របខណ្ឌស្ថាប័នព័ត៌មានអាស៊ាន ដែលតម្រូវឱ្យស្ថាប័នព័ត៌មានកម្ពុជាធ្វើការប្រយុទ្ធប្រឆាំងព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយឱ្យកាន់តែសកម្មថែមទៀត។ នេះជាការបញ្ជាក់បន្ថែមរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។

លោកបានសង្កត់ធ្ងន់ថា ៖ «ព្រោះព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយ ជាផ្នែកចិត្តសាស្ត្រដែលអាចធ្វើឱ្យសង្គម ទាំងមូលមានភាពចលាចលអស្ថេរភាពនយោបាយ អសន្តិសុខសង្គម និងកើតមានអរិភាពជាមួយបរទេស»។

យោងតាមគណៈកម្មការតាមដានការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយនៃក្រសួងព័ត៌មានដែលបានស្រង់ប្រភពផ្សព្វផ្សាយសារ និងវីដេអូពាក់ព័ន្ធនឹងដំណឹងក្លែងក្លាយ ព័ត៌មានមិនពិត ញុះញង់បំពុលសង្គម និងជេរប្រមាថថ្នាក់ដឹកនាំ សរុបចំនួន ១ ៩៣៨ ករណី ក្នុងឆ្នាំ ២០២១ ដែលករណីនេះ មានការកើនឡើងបន្តិចបន្តួច បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០២០ ។

របាយការណ៍ដដែលបានឱ្យដឹងថា ក្នុងចំណោមករណីដែលត្រូវបានរកឃើញទាំងនោះរួមមាន ញុះញង់រិះគន់រាជរដ្ឋាភិបាល និងប្រឌិតបំភ្លៃការពិតចំនួន ១ ០២៣ ករណី ជេរប្រមាថព្រះមហាក្សត្រ និងថ្នាក់ដឹកនាំចំនួន ៨០៩ ករណី ព័ត៌មានមិនពិត និង បំពុលសង្គមចំនួន ១០៦ ករណី។

ស្របពេលជាមួយគ្នានេះដែរ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក៏បានឱ្យសមាគមអ្នកសារព័ត៌មានទាំងអស់ត្រូវបន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈ សមត្ថភាពជំនាញដល់បុគ្គលិក និងភ្នាក់ងាររបស់ខ្លួនឱ្យដើរទាន់ការវិវត្តនៃបច្ចេកវិទ្យា ប្រព័ន្ធផ្សព្វផ្សាយឌីជីថល។

ការបណ្តុះនេះវានឹងអាចជួយបំពេញការងារបានរហ័សទាន់សភាពការណ៍ និងត្រូវបង្កើតឡើងនូវកាលានុវត្តភាពថ្មីមួយសម្រាប់ទប់ទល់នឹងបញ្ហាប្រឈមនានា ដែលអាចនឹងកើតមាននៅពេលអនាគត ដែលមិនអាចប៉ាន់ស្មានបាន។

លោកមានប្រសាសន៍ថា៖ «ខ្ញុំក៏សូមកោតសរសើរចំពោះសមាគមអ្នកសារព័ត៌មានទាំងអស់



*លោក ហ៊ុយ វណ្ណៈ ប្រធានសហភាពសហព័ន្ធអ្នកសារព័ត៌មានកម្ពុជា។*



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
តារាងឈ្មោះទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ (SinoVac) ក្នុងរាជធានីភ្នំពេញ
ជុំសទី១ ចាប់ពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ ដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១
ជុំសទី២ ចាប់ពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១







«ត្រូវហ៊ានបញ្ចេញនូវព័ត៌មានពិត មិនក្លែងបន្លំ បំភ្លៃការពិត និងត្រូវបន្តបំផ្លាញចោលពួកឱកាសនិយមស្វែងយកផលប្រយោជន៍ផ្ទាល់ខ្លួនជ្រកក្រោមស្លាកសារព័ត៌មានធ្វើឱ្យប៉ះពាល់ដល់តម្លៃ កិត្យានុភាពរបស់អ្នកសារព័ត៌មានទូទៅនិងស្ថាប័នសារព័ត៌មាន»












*លោក ណុប វី នាយកប្រតិបត្តិសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)*

«ការមិនបានបំពេញនូវវិជ្ជាជីវៈត្រឹមត្រូវ និងការប្រើប្រាស់វិជ្ជាជីវៈដើម្បីប្រយោជន៍ផ្ទាល់ខ្លួន វានឹងធ្វើឱ្យអ្នកសារព័ត៌មាននោះនឹងបាត់បង់តម្លៃ បាត់បង់ការគាំទ្រ នោះប្រព័ន្ធព័ត៌មានរបស់ពួកគាត់នឹងមិនអាចដំណើរការទៀតដែរ»

ដែលបានខិតខំ ប្រឹងប្រែងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតម្រង់ទិសអ្នកសារព័ត៌មានទាំងអស់ឱ្យធ្វើជាកញ្ចក់ឆ្លុះបញ្ចាំង តថភាពក្នុងសង្គម និងការបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌ វិជ្ជាជីវៈដើម្បីលើកកម្ពស់តម្លៃ និង កិត្យានុភាពរបស់ស្ថាប័នព័ត៌មាននិងអ្នកសារព័ត៌មានទូទៅ»។

ប្រធានសហភាពសហព័ន្ធអ្នកសារព័ត៌មានកម្ពុជា លោក ហ៊ុយ វណ្ណៈ បានបង្ហាញពីការគាំទ្រនូវការលើកឡើងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពីតួនាទីដ៏សំខាន់របស់អ្នកសារព័ត៌មាន។ លោកបានថ្លែងថា ៖ «ខ្ញុំសរសើរបងប្អូនសារព័ត៌មានអាជីពដែលរក្សាបាននូវគុណតម្លៃតួនាទីខ្លួនប្រកបដោយវិជ្ជាជីវៈល្អប្រសើរ ប៉ុន្តែយើងក៏មានការសោកស្តាយចំពោះបងប្អូនអ្នកសារព័ត៌មានអនឡាញមួយចំនួនតូចដែលធ្វើសកម្មភាពមិនត្រឹមត្រូវ ធ្វើឱ្យជះរូបភាពមិនល្អដល់តួនាទីសារព័ត៌មានជាទូទៅ»។

លោក ហ៊ុយ វណ្ណៈ តែងតែចែករំលែកថាការងារជាអ្នកសារព័ត៌មាន មិនមែនធ្វើដើម្បីដូរជុំបាយនោះទេ ប៉ុន្តែសារព័ត៌មាន គឺជាការងារបញ្ញវន្តជួរមុខផ្នែក «មនសិការ និង ឧត្តមគតិ» ថ្លៃថ្នូរ ខ្ពង់ខ្ពស់ ដែលបម្រើដល់ផលប្រយោជន៍មនុស្សជាតិ។

លោកថា ៖ «មហាជនគោរពយើង គឺនៅលើតម្លៃនៃចំណេះដឹង ផ្សាយការពិត និងមានក្រមសីលធម៌វិជ្ជាជីវៈ។ អ្នកសារព័ត៌មាន តោងរំលឹកខ្លួនឯងជាប្រចាំថា យើងមិនមែនជាសកម្មជន មិនមែនជាចៅក្រម កុំជោ ហើយកុំសម្តែង»។

ប្រធានសហភាពសហព័ន្ធអ្នកសារព័ត៌មានកម្ពុជារូបនេះបានបញ្ជាក់ទៀតថា សារព័ត៌មានត្រូវខិតខំអភិវឌ្ឍខ្លួនជាបញ្ញវន្តដែលមានទស្សនវិស័យវែងឆ្ងាយ ជាតិនិយម ហើយសារព័ត៌មាន ជាវិជ្ជាជីវៈដែលមានចំណែកធំណាស់ក្នុងសង្គមជាតិលើផ្នែកប្រាជ្ញា ស្មារតី ឧត្តមគតិ ការផ្សព្វផ្សាយជាតិ។

លោកថា ៖ «វិជ្ជាជីវៈនីមួយៗ ដែលទទួលបានការគោរព ការជឿទុកចិត្តពីសាធារណៈជន គឺអាស្រ័យក្រមសីលធម៌នេះឯង មុនគេបំផុត។ បើសីលធម៌ធ្លាក់ចុះ គឺអ្វីៗ នឹងធ្លាក់ចុះទៅតាមគ្នា។ នៅពេលបាត់បង់នូវជំនឿទុកចិត្តនិងការគោរព គឺប្រែថា ស្លាប់»។

លោក ហ៊ុយ វណ្ណៈ ក៏បានរំលឹកដល់អ្នកសារព័ត៌មានត្រូវបន្តប្រយ័ត្នប្រយែង ផ្ទៀងផ្ទាត់ប្រភពព័ត៌មានឱ្យបានច្បាស់ មុននឹងផ្សាយ ជៀសវាងកុំឱ្យក្លាយជាអ្នកបន្ទរ ព័ត៌មានក្លែងក្លាយ។ វិធីនេះក៏ជាការចូលរួមដ៏សំខាន់ ក្នុងការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់ដល់ការគិត និងសង្គមជាតិយើងផ្នែកណាមួយនោះ»។

រីឯលោក ណុប វី នាយកប្រតិបត្តិសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) ក៏បានបង្ហាញពីការគាំទ្រនូវការលើកឡើងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនដូចគ្នាផងដែរ ប៉ុន្តែលោកថារដ្ឋាភិបាលគួរតែពង្រឹងនូវការផ្តល់ការការពារសុវត្ថិភាព សន្តិភាពឱ្យបានពេលលេញចំពោះអ្នកសារព័ត៌មានដែលបានបំពេញភារកិច្ចតាមវិជ្ជាជីវៈពិត។

លោកបានថ្លែងបញ្ជាក់ផងដែរថា៖ «ខ្ញុំយល់ថាលោកនាយករដ្ឋមន្ត្រីមិនគួរណាធ្វើការបំផ្លាញចោលចំពោះសារព័ត៌មានណាដែលមិនទាន់បានអនុវត្តនូវគោលការណ៍ក្រមសីលធម៌ វិជ្ជាជីវៈពេញលេញនៅឡើយទេ។ ខ្ញុំមិនគាំទ្រចំពោះការឱ្យបំផ្លាញចោលពួកឱកាសនិយមស្វែងយកផលប្រយោជន៍ផ្ទាល់ខ្លួនជ្រកក្រោមស្លាកសារព័ត៌មានទេ ពីព្រោះជាធម្មតាវាជាសេរីរបស់អ្នកសារព័ត៌មាន ដែលសេរីភាពនោះមិនគួរត្រូវបានគំរាមកំហែង បំភិតបំភ័យឡើយ»។

លោក ណុប វី បានបញ្ជាក់ថា ការមិនបានបំពេញនូវវិជ្ជាជីវៈត្រឹមត្រូវ និងការប្រើប្រាស់វិជ្ជាជីវៈដើម្បីប្រយោជន៍ផ្ទាល់ខ្លួន វានឹងធ្វើឱ្យអ្នកសារព័ត៌មាននោះនឹងបាត់បង់តម្លៃ បាត់បង់ការគាំទ្រ នោះប្រព័ន្ធព័ត៌មានរបស់ពួកគាត់នឹងមិនអាចដំណើរការទៀតដែរ៕

# ធនាគារពិភពលោកអនុម័តជំនួយហិរញ្ញប្បទានជិត ៧០ លានដុល្លារអាមេរិក ជួយដល់ការអប់រំនៅកម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

ធនាគារពិភពលោក (World Bank) បានអនុម័តជំនួយហិរញ្ញប្បទានសរុបចំនួន ៦៩,២៥លានដុល្លារអាមេរិក ដែលក្នុងនោះមានអំណោយពីអង្គការភាពជាដៃគូសាកលដើម្បីការអប់រំ ដើម្បីជួយកម្ពុជាក្នុងការធ្វើឱ្យកាន់តែប្រសើរនូវលទ្ធភាពប្រកបដោយសមធម៌ក្នុងការទទួលបានការ អប់រំជាមូលដ្ឋាន និងឆ្លើយតបឱ្យបានរហ័សទៅនឹងវិបត្តិនានាដែលប៉ះពាល់ដល់ប្រព័ន្ធអប់រំក្នុងប្រទេស។

តាមសេចក្តីប្រកាសព័ត៌មានរបស់ធនាគារពិភពលោកបានឱ្យដឹងថា កញ្ចប់មូលនិធិថ្មីនេះរួមមានទឹកប្រាក់ចំនួន ៦០លានដុល្លារអាមេរិក ដែលធនាគារពិភពលោកនឹងផ្តល់ជាឥណទានតាមរយៈសមាគមអភិវឌ្ឍន៍អន្តរជាតិ និងចំនួន ៩,២៥លានដុល្លារអាមេរិកទៀត ជាជំនួយឥតសំណងពីអង្គការភាពជាដៃគូសាកលដើម្បីការអប់រំ។

ធនាគារពិភពលោកបញ្ជាក់ថា៖«ហិរញ្ញប្បទាននេះនឹងជួយទ្រទ្រង់ដល់គម្រោងកែលម្អការអប់រំទូទៅដែលមានរយៈពេលប្រាំឆ្នាំ ជាមួយគោលបំណងជួយកម្ពុជាក្នុងការឈានទៅសម្រេចចក្ខុវិស័យនៃផែនការយុទ្ធសាស្ត្រនៃការអប់រំ ឆ្នាំ២០១៩-២០២៣»។

ចក្ខុវិស័យនោះគឺឆ្ពោះទៅបង្កើត និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពខ្ពស់និងសីលធម៌ល្អ ដើម្បីអភិវឌ្ឍឱ្យបានសង្គមមួយដែលមានចំណេះដឹងជាមូលដ្ឋាន។

ដើម្បីឈានទៅសម្រេចកម្មវត្ថុនេះ រដ្ឋាភិបាលកម្ពុជាបានបង្ហាញការប្តេជ្ញាចិត្តលៃលករកដំណោះស្រាយដល់បញ្ហាប្រឈមធំពីរ គឺការរៀនចេះរបស់សិស្សនៅមានកម្រិតទាប និងវិសមធម៌ក្នុងលទ្ធភាពទទួលបានការអប់រំជាមូលដ្ឋាន ក្នុងនោះ រួមមានការអប់រំសម្រាប់ក្មេងតូច, ការអប់រំកម្រិតបឋម និងការអប់រំកម្រិតមធ្យមសិក្សាចំណេះទូទៅ។



THE WORLD BANK

ប្រធានគ្រប់គ្រងនៃធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា លោកស្រី ម៉ារីយ៉ាម សាលីម បានថ្លែងថា កម្ពុជាពិតជាបានសម្រេចសមិទ្ធផលធំៗច្រើននៅក្នុងការពង្រីកលទ្ធភាពទទួលបានការអប់រំ ប៉ុន្តែបញ្ហានៅបន្តមាននៅឡើយពាក់ព័ន្ធទៅនឹងលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌។

លោកស្រីបានថ្លែងថា៖«ជាពិសេសសម្រាប់កុមារច្រើនក្រុម មានដូចជា កុមាររស់នៅតាមតំបន់ដាច់ស្រយាល កុមារក្នុងគ្រួសារក្រីក្រ ឬក្នុងបណ្តាសហគមន៍ជនជាតិដើមភាគតិច និងកុមារមានពិការភាព»។

លោកស្រី ម៉ារីយ៉ាម សាលីម បានបន្តថា លទ្ធផលនៃការរៀនចេះរបស់សិស្សបានរងការប៉ះទង្គិចយ៉ាងខ្លាំងនៅពេលដែលសាលារៀនត្រូវបានបិទទ្វារយ៉ាងយូរ ដោយសារតែការរាតត្បាតនៃជំងឺកូវីដ-១៩ ។

លោកស្រីសង្កត់ធ្ងន់ថា៖«យើងសង្ឃឹមយ៉ាងមុតមាំថា គម្រោងនេះនឹងរកដំណោះស្រាយដល់បញ្ហាប្រឈមទាំងនេះ និងស្តារការអប់រំឱ្យកាន់តែមានភាពប្រសើរឡើងវិញថែមទៀត»។

ចំណែកលោកស្រី អាលីស អលប្រាយ នាយិកាប្រតិបត្តិនៃអង្គការភាពជាដៃគូសាកលដើម្បីការអប់រំ បានលើកឡើងថា ការផ្តល់ជំនួយហិរញ្ញវត្ថុនេះគឺចំពេលដ៏សំខាន់ ក្នុងខណៈដែលវិរុសបំប្លែងនៃកូវីដ-១៩ កំពុងបង្កផលប៉ះពាល់កាន់តែអាក្រក់ទៅលើប្រព័ន្ធអប់រំនៅទូទាំងពិភពលោក។

លោកស្រីថា ៖ «យើងសង្ឃឹមថា ជំនួយទាំងនេះនឹងជួយកម្ពុជាឱ្យបន្តពង្រីកលទ្ធភាពក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព និងធានាយ៉ាងណាឱ្យកុមារក្នុងក្រុមងាយរងគ្រោះបំផុតបានចូលសាលារៀន និងទទួលចំណេះដឹងផង»។

គម្រោងនេះមានសកម្មភាពធំៗ ដូចជាការអនុវត្តកម្មវិធីគ្រប់គ្រងនៅតាមសាលារៀន, ការផ្តល់ការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀនថ្នាក់ដឹកនាំសាលា គ្រូបណ្តុះបណ្តាល និងបុគ្គលិកសិក្សា, និងការកែលម្អបរិយាកាសរៀនឱ្យប្រសើរឡើងថែមទៀត។

គម្រោងនេះមានការសាងសង់ និង ស្តារជួសជុលឡើងវិញនូវអគារសិក្សា, មន្ទីរពិសោធន៍វិទ្យាសាស្ត្រ, ស្ថាប័នបណ្តុះបណ្តាលគ្រូ និងសាលាអប់រំពិសេស ការទិញគ្រឿងបរិក្ខារបច្ចេកវិទ្យាសម្រាប់ការអប់រំ និងការជួយដល់សិស្សមានពិការភាព។ ក្រៅពីនេះ គម្រោងនៅមានការសាកល្បងកម្មវិធីអប់រំបច្ចេកវិទ្យាមួយសម្រាប់មុខវិជ្ជាគណិតសាស្ត្រក្នុងគោលដៅសំខាន់ៗផងដែរ៕

# អ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ហាក់មានការកើនឡើងជាងអ្នកស្លាប់ដោយសារកូវីដ បន្ទាប់ពីបើកប្រទេសឡើងវិញ

*អត្ថបទ៖ អមរិន្ទ ដានុត*

ស្របពេលដែលចំនួនអ្នកស្លាប់ដោយសារជំងឺកូវីដ១៩ មានការថយចុះច្រើន អត្រាអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍បានហក់ឡើងគួរឱ្យព្រួយបារម្ភ បន្ទាប់ពីរាជរដ្ឋាភិបាលសម្រេចឱ្យបើកដំណើរការប្រទេសឡើងវិញ។ នេះជាការលើកឡើងរបស់លោកនាយករដ្ឋមន្ត្រីហ៊ុន សែន ខណៈដែលតួលេខនៃអ្នកស្លាប់ដោយសារកូវីដ១៩ក្នុងរយៈពេលចុងក្រោយនេះមិនមានអ្នកស្លាប់ឡើយ។

លោក ហ៊ុន សែន បានមានប្រសាសន៍ថា បញ្ជាក់ថា៖ «កន្លងមកនេះ ក្នុងរយៈពេលនៃការឆ្លងរាលដាលនៃវីរុសកូវីដ-១៩ អ្នកស្លាប់ពីគ្រោះថ្នាក់ចរាចរណ៍មានចំនួនតិចជាងស្លាប់ដោយសារកូវីដ១៩ ដោយសារពេលនោះយើងមិនទាន់បើកប្រទេស។ ពេលនេះយើងបានបើកដំណើរការប្រទេសឡើងវិញ ដូច្នេះការធ្វើដំណើរត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់»។

បើយោងតាមរបាយការណ៍របស់ក្រសួងមហាផ្ទៃ បានឱ្យដឹងថា គ្រោះថ្នាក់ចរាចរណ៍ឆ្នាំ២០២១កន្លងទៅនេះ អត្រាគ្រោះថ្នាក់ចរាចរ និងអ្នករងគ្រោះបាត់បង់ជីវិតមានការថយចុះច្រើនបើប្រៀបធៀបនឹងឆ្នាំ២០២០ដែលពុំសូវមានការធ្វើដំណើរមមាញឹក ដោយសារស្ថានភាពនៃការរាតត្បាតជំងឺកូវីដ-១៩ ។

ប្រភពដដែលបានបន្តថា ទិន្នន័យគ្រោះថ្នាក់ចរាចរណ៍ពេញមួយឆ្នាំ២០២១នេះគឺមានចំនួន ២ ៦៧០ លើក បើប្រៀបធៀបនឹងឆ្នាំ២០២០មានចំនួន៣ ១៧៦ លើកគឺមានការថយចុះ១៦ភាគរយ។

រីឯចំនួនអ្នកស្លាប់បាត់បង់ជីវិតមានចំនួន ១ ៤៩៧ នាក់ បើប្រៀបធៀបនឹងឆ្នាំ២០២០ មានចំនួន១ ៦៤៦នាក់ មានការថយចំនួន ១៤៩នាក់ស្មើនឹង៩ភាគរយ។ ចំណែកអ្នករងរបួសមានចំនួន ៣៦១៥នាក់ មានការថយចុះ ១ ០៧១នាក់ ស្មើនឹង២៣ភាគរយ បើប្រៀបធៀបនឹងឆ្នាំ២០២០ដែលមានអ្នករងរបួសរហូតដល់ ៤ ៦៨៦នាក់។

លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានលើកឡើងថា ការថយចុះគ្រោះថ្នាក់ចរាចរណ៍ អាត្រាអ្នកស្លាប់ និងរងរបួសនេះបានបង្ហាញពីមោទនភាពនៃការចូលរួមរបស់ប្រជាពលរដ្ឋទាំងអស់ ក្នុងការគោរពច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ដែលបានប្រតិបត្តិការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដោយស្មារតីវិជ្ជាជីវៈយ៉ាងសកម្ម។

លោកមានប្រសាសន៍ថា៖«ទោះបីជាលទ្ធផលបានបង្ហាញពីការថយចុះគ្រោះថ្នាក់ចរាចរណ៍ ទាំងអាត្រាអ្នកស្លាប់ និងរងរបួសយ៉ាងដូច្នេះក្តី ប៉ុន្តែស្ថានភាពគ្រោះថ្នាក់ចរាចរណ៍នៅពេលនេះ នៅតែជាសោកនាដកម្មសម្រាប់ប្រជាពលរដ្ឋខ្មែរនៅឡើយដោយធ្វើឲ្យមនុស្សច្រើនរាប់ពាន់នាក់ក្នុងមួយឆ្នាំៗបានបាត់បង់ជីវិត រងរបួស និងខូចខាតទ្រព្យសម្បត្តិ»។

តាមផ្នែកជំនាញបានរកឃើញពីមូលហេតុនៃគ្រោះថ្នាក់ចរាចរណ៍នៅឆ្នាំ២០២១នេះ គឺដោយសារការបើកបរដោយល្បឿនលឿនចំនួន៣៨ភាគរយ ការមិនគោរពសិទ្ធមានចំនួន២៤ភាគរយ ការមិនប្រកាន់ស្តាំមានចំនួន១៤ភាគរយ ការប្រជែងគ្រោះថ្នាក់មាន៨ភាគរយ បត់ឆ្វេង-ស្តាំមិនប្រយ័ត្នមាន៨ភាគរយ ស្រវឹង៤ភាគរយ កត្តាយានយន្តមាន៣ភាគរយ និងងងុយមាន១ភាគរយ ។

ជាមួយគ្នានេះដែរ ក្រើនរំលឹកដល់មន្ត្រីមានសមត្ថកិច្ចដឹកនាំ និងប្រតិបត្តិការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកទាំងអស់បង្កើនការបន្តរឹតបន្តឹងការអនុវត្តច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោកឱ្យបានសកម្ម គ្មានការលើកលែង ឬយោគយល់អ្វីទាំងអស់៕

# អ្នកជំនាញអង្គការសហប្រជាជាតិថា ការចាប់ខ្លួនកូដករអាចជាការបំពានលើច្បាប់សិទ្ធិមនុស្ស តែកម្ពុជាថាស្របនឹងច្បាប់




*អត្ថបទ៖ អមរិន្ទ ដានុត*

ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញបានសម្រេចចោទប្រកាន់ថ្នាក់ដឹកនាំ និងសមាជិកសហជីពនៃក្រុមហ៊ុនណាហ្គាវើលដ៏ (NAGA World) ចំនួន ៩នាក់ ពីបទ «ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម យោងតាមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ និងបានបញ្ជូនទៅឃុំខ្លួនផងដែរកាលពីចុងឆ្នាំ២០២១និងដើមឆ្នាំ២០២២កន្លងមកនេះ។

បន្ទាប់ពីមានការចាប់ ចោទប្រកាន់ និងឃុំខ្លួនថ្នាក់ដឹកនាំនិងសមាជិកទាំងនេះ បណ្តាក្រុមសង្គមស៊ីវិល សហភាពសហជីព សហព័ន្ធសហជីព និងសមាគម ជាច្រើនស្ថាប័ន បានចេញសេចក្តីថ្លែងការណ៍និងស្នើឱ្យអាជ្ញាធរដោះលែងថ្នាក់ដឹកនាំ និងសមាជិកសហជីពណាហ្គាវើលដ៏ និងគោរពសិទ្ធិការងាររបស់និយោជិតជាបន្តបន្ទាប់ ប៉ុន្តែមិនត្រូវបានសម្រេចឡើយ។

ជាមួយគ្នានេះដែរ ក្រុមអ្នកជំនាញរបស់អង្គការសហប្រជាជាតិក៏បានលើកឡើងថា ការចាប់ និងឃុំខ្លួនអ្នកដឹកនាំ និងសកម្មជនសហជីពកាស៊ីណូ ក្នុងអំឡុងពេលធ្វើកូដកម្មជាបន្តបន្ទាប់អាចជាការរំលោភបំពានលើច្បាប់សិទ្ធិមនុស្ស។

ក្រុមអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យបានមានប្រសាសន៍ថា៖ «ការចាប់ខ្លួនកូដករដែលភាគច្រើនជាស្ត្រី ជាច្រើនលើកទាំងនេះត្រូវបានធ្វើឡើងយ៉ាងហិង្សា និងមើលទៅជាការបំពានលើសេរីភាពក្នុងការបង្កើតសមាគម ការប្រមូលផ្តុំ និងការបញ្ចេញមតិ»។

ក្រុមអ្នកជំនាញបានអំពាវនាវឲ្យរាជរដ្ឋាភិបាលធ្វើការពន្យល់នូវសកម្មភាពឆ្លើយតបរបស់មន្ត្រីនគរបាល ហើយក៏បញ្ជាក់ថាពួកគាត់កំពុងតាមដានការវិវត្តន៍នេះយ៉ាងដិតដល់។

អ្នកដឹកនាំ និងសកម្មជនសហជីពបានធ្វើកូដកម្មចាប់ពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ ដើម្បីជាការតវ៉ានូវពួកគាត់ចាត់ទុកថាជាការបណ្តេញចេញពីការងារដោយអយុត្តិធម៌សម្រាប់បុគ្គលិកនិយោជិតចំនួន ៣៦៥នាក់ របស់កាស៊ីណូ និងរីសត ណាហ្គាវើលដ៍ បន្ទាប់ពីការចរចាមិនបានសម្រេចច្រើនលើកជាមួយនិយោជក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជ្ញាធររាជធានីភ្នំពេញ។

ដោយឡែក ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅទីក្រុងហ្សឺណែវ បានធ្វើការអះអាងថា ចំណាត់ការនានារបស់អាជ្ញាធរកម្ពុជាគឺស្របទៅនឹងច្បាប់ និងមានលក្ខណៈសមាមាត្រ។

ស្ថានបេសកកម្ម បានធ្វើការបដិសេធចោលទាំងស្រុងនូវការលើកឡើងដោយគ្មានទំនួលខុសត្រូវ និងបង្កការភ័ន្តច្រឡំ ផ្អែកលើព័ត៌មានជ្រើសរើសតែមួយជ្រុង និងពុំបានផ្ទៀងផ្ទាត់ត្រឹមត្រូវ





របស់អ្នករាយការណ៍ពិសេសចំនួនបួនរូប ពាក់ព័ន្ធការអនុវត្តច្បាប់ទៅលើសកម្មភាពកូដកម្មខុសច្បាប់ដែលបានអូសបន្លាយជាច្រើនសប្តាហ៍ នៅកម្ពុជា។ ស្ថានបេសកកម្មកម្ពុជា បានបញ្ជាក់ថា ៖ «នៅមុនការអនុវត្តច្បាប់ អាជ្ញាធរមានសមត្ថកិច្ចបានអំពាវនាវយ៉ាងទទូចស្នើឱ្យនយោជិតដែលធ្វើកូដកម្ម ងាកមកចរចាដោយសន្តិវិធីត្រង់ទៅត្រង់មក និងបញ្ឈប់ការធ្វើបាតុកម្មខុសច្បាប់របស់ខ្លួន»។

ការចោទប្រកាន់របស់អាជ្ញាធរបានធ្វើឡើងដោយ ផ្អែកលើមូលដ្ឋានភស្តុតាងរឹងមាំនិងគ្រប់គ្រាន់ រួមទាំងការឆ្លើយសារភាពរបស់កូដករខ្លះ និងប្រភពហិរញ្ញវត្ថុចិញ្ចឹមចលនារបស់តួអង្គបរទេសមួយចំនួន និងដោយអនុលោមតាមមាត្រា៤៩៤ និង៤៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា ដែលត្រូវបានតាក់តែងឡើងដោយមានជំនួយពី អ្នកជំនាញពីប្រទេសលោកខាងលិច។

ក្រុមអតីតបុគ្គលិកក្រុមហ៊ុនណាហ្គាវើលដ៍ នៅតែបន្តការតវ៉ាដដែលដោយទាមទារឱ្យមានការដោះលែងថ្នាក់ដឹកនាំនិងសមាជិកចំនួន៩នាក់ និងដោះស្រាយបញ្ហាជូនពួកគាត់។ ជាមួយនេះដែរ ក្រុមអ្នកតវ៉ាទាំងនេះនឹងដាក់ញត្តិនៅស្ថានទូតចំនួន៨ទៀត នៅថ្ងៃទី១៨ ខែមករា ក្នុងនោះមានស្ថានទូតអាមេរិក អូស្ត្រាលី សាធារណៈឆេក សាធារណៈរដ្ឋកូរ៉េ ឥណ្ឌា ជប៉ុន ម៉ាឡេស៊ី និងឥណ្ឌូណេស៊ី៕

# ក្រសួងធំៗចំនួន២ រួមគ្នាអំពាវនាវឱ្យមានការទប់ស្កាត់ភ្លើងឆេះព្រៃ ក្នុងតំបន់ការពារធម្មជាតិ

*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រសួងចំនួនពីរបានធ្វើការអំពាវនាវនិងចេញនូវវិធានការការពារ និងទប់ស្កាត់ភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ខណៈដែលនៅរដូវប្រាំង ធាតុអាកាសទូទៅនៅប្រទេសកម្ពុជាមានសភាពក្តៅហួតហែង និងស្ងួតខ្លាំង ដែលងាយនឹងបង្កឱ្យមានកត្តាភ្លើងឆេះព្រៃ។

លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកឡើងថា ជារៀងរាល់ឆ្នាំ ធាតុអាកាសទូទៅនៅក្នុងប្រទេសកម្ពុជាចាប់ផ្តើមផ្លាស់ប្តូររដូវវស្សាចូលដល់រដូវលំហើយ រួចបន្តចូលរដូវប្រាំង ដែលធាតុអាកាសមានសភាពក្តៅហែង ស្ងួតខ្លាំង ជាកត្តាងាយបង្កនូវភ្លើងឆេះព្រៃ។

លោកបានបន្តថា ៖ «ក្រៅពី បាតុភូតធម្មជាតិដែលអាចបង្កឱ្យមានភ្លើងឆេះព្រៃ ប្រការដែលគួរឱ្យព្រួយបារម្ភបំផុតនោះគឺភ្លើងឆេះព្រៃដែលបង្កឡើង ដោយសារសកម្មភាពរបស់មនុស្សផ្ទាល់។ កត្តាចម្បងគឺការកាប់ឆ្ការដុតរានព្រៃដើម្បីដាំដំណាំកសិកម្មផ្សេងៗ ការធ្វើកសិកម្មពនេចរ ការតាំងទី លំនៅដ្ឋានថ្មី ការដុតព្រៃដើម្បីចាប់សត្វ ការបន្សល់ដើមភ្លើងនៅក្នុងព្រៃតាមរយៈការធ្វេសប្រហែសរបស់មនុស្ស»។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានកត់សម្គាល់ឃើញថា ភ្លើងឆេះព្រៃជារៀងរាល់ឆ្នាំបានបង្កឱ្យមានបញ្ហាដ៏ធ្ងន់ធ្ងរដល់ការបាត់បង់ធនធានព្រៃឈើ ព្រៃលិចទឹក និងវាលដាលរហូតដល់ឆេះស្រូវ និងភូមិកររបស់ប្រជាពលរដ្ឋទៀតផង។

រដ្ឋមន្ត្រីរូបនេះបានបញ្ជាក់ថា ក្នុងករណីចាំបាច់ដែលត្រូវប្រើភ្លើងជាមធ្យោបាយក្នុងការដុតកាកសំណល់ឈើព្រៃ ក្រោមគោលបំណងដាំដំណាំកសិកម្ម និងសកម្មភាពស្របច្បាប់ផ្សេងទៀត ត្រូវជូនដំណឹងដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត ដើម្បីណែនាំអនុវត្តវិធានការបច្ចេកទេសសមស្របដែលអាចធានាសុវត្ថិភាពចំពោះភ្លើងព្រៃ។

ចំណែកក្រសួងបរិស្ថាន ក៏បានលើកឡើងដែរថា ប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសក្នុងតំបន់បាននិងកំពុងទទួលរងឥទ្ធិពលបាតុភូតឡានីណា (La Nina) ក៏ដោយ តែក្រៅពីបាតុភូតធម្មជាតិ ដែលបង្កឱ្យមានភ្លើងឆេះព្រៃ ហានិភ័យនៃភ្លើងឆេះព្រៃដែលបង្កដោយសកម្មភាពរបស់មនុស្សផ្ទាល់ ក៏ជាកត្តាចម្បងមួយគួរឱ្យកត់សម្គាល់ និងព្រួយបារម្ភផងដែរ។

តាមការកត់សម្គាល់របស់ក្រសួងបរិស្ថាន បញ្ហាភ្លើងឆេះព្រៃតែងតែកើតមាននៅក្នុងតំបន់ការពារ ធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិនានារបស់ប្រទេសកម្ពុជាជារៀងរាល់ឆ្នាំ ជាពិសេសនៅក្នុងរដូវប្រាំង។

ក្រសួងបរិស្ថាន បានអំពាវនាវ និងធ្វើការណែនាំដល់អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរបរិស្ថានរាជធានី-ខេត្ត អាជ្ញាធរ មានសមត្ថកិច្ច រួមទាំងសហគមន៍តំបន់ការពារធម្មជាតិ ប្រជាសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំង អស់ធ្វើការផ្សព្វផ្សាយពីការប្រុងប្រយ័ត្នភ្លើងឆេះព្រៃនេះ។

មន្ទីរបរិស្ថានរាជធានី-ខេត្ត ត្រូវណែនាំអ្នកពាក់ព័ន្ធ អនុវត្តវិធានការបច្ចេកទេសសមស្រប ដែល អាចធានាសុវត្ថិភាពចំពោះភ្លើងព្រៃ ដោយត្រូវពន្លត់ភ្លើងឱ្យអស់ជាចាំបាច់មុនពេលចាកចេញពីទីតាំងប្រើប្រាស់ ភ្លើងនោះ។

ក្រសួងបរិស្ថានបានសង្កត់ធ្ងន់ថា ៖ «អនុលោមតាមមាត្រា៦២ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិបានចែងថា ការបង្កឱ្យមានភ្លើងឆេះ ព្រៃដោយចេតនា ជាបទល្មើសធនធានធម្មជាតិថ្នាក់ទី៤ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំ ដល់១០ឆ្នាំ និងផាកពិន័យជាប្រាក់ពី១៥លានរៀល ដល់ ១៥០លានរៀល»៕

# កុមារជំទង់៨៧នាក់ចូលរួមសិក្ខាសាលា "មិត្តសម្លាញ់ជីវិត"





*អត្ថបទ៖ ដាលីស*

កុមារជំទង់អាយុ១៣ដល់១៧ឆ្នាំចំនួន ៨៧នាក់ មកពី៤មណ្ឌលសកម្មភាពនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ចូលរួមសិក្ខាសាលាក្រោមប្រធានបទ «មិត្តសម្លាញ់ជីវិត» ដែលដឹកនាំដោយ ការិយាល័យយុវជនជំទង់ កុមារ និងគ្រួសារនៃព្រះសហគមន៍ភូមិភាគភ្នំពេញ។

កម្មវិធីនេះ បានប្រព្រឹត្តឡើងរយៈពេល២ថ្ងៃ ពីថ្ងៃទី១៥ ដល់ ទី១៦ ខែមករា ឆ្នាំ២០២២ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល ភ្នំពេញថ្មី។

តាមការឱ្យដឹងពីកញ្ញា នៅ ម៉ាលីន អ្នកទទួលខុសត្រូវកម្មវិធីជំទង់ បានឱ្យដឹងថា កម្មវិធីសិក្ខាសាលានេះធ្វើឡើងក្នុងគោលបំណងសំខាន់ៗ គឺដើម្បីពង្រឹងផ្លូវវិញ្ញាណរបស់ជំទង់ឱ្យកាន់តែរឹងមាំ និងការចែករំលែកបទពិសោធជីវិតជាបទពិសោធនៃរបៀបរស់នៅ។

កញ្ញាបានឱ្យដឹងថា ៖ «គោលបំណងបន្ទាប់គឺឱ្យគាត់រៀនរស់នៅជាមួយព្រះសហគមន៍យ៉ាងជិតស្និទ្ធដោយចូលរួមបម្រើព្រះសហគមន៍កាន់តែច្រើន និងការណែនាំឱ្យពួកគាត់មានអំណរសប្បាយដោយសារយើងខានចួបជុំគ្នាជាយូរមកហើយ»។

កញ្ញា ម៉ាលីន បានបន្ថែមថា កម្មវិធីលើកនេះ កុមារទាំងអស់មានការចាប់អារម្មណ៍ខ្លាំងទៅលើប្រធានបទ ដោយមិត្តសម្លាញ់ធ្វើឱ្យគាត់មានអារម្មណ៍ថាជិតស្និទ្ធ និងត្រូវរក្សាការពារ។ អ្នកចូលរួមក្នុងកម្មវិធីលើកនេះ មានជំទង់ខ្លះ មិនដែលស្គាល់ព្រះសហគមន៍សោះ ក៏មានចំណាប់អារម្មណ៍ចូលរួមចង់ស្គាល់ព្រះសហគមន៍ និងអ្វីផ្សេងៗដែលពាក់ព័ន្ធនឹងព្រះសហគមន៍ ជាពិសេសប្រធានបទតែម្តង។

យុវតីរូបនេះបានបញ្ជាក់ថា៖ «ពួកគាត់បានចាប់យកនូវអ្វីដែលកម្មវិធីយើងបានដាក់ និងអនុវត្តបានល្អមែនទែន និងជាពិសេសក្រុមមនុស្សជំទង់ទាំងនេះបានចូលរួមការពារបរិស្ថាន ទាំងព្រះសហគមន៍ និងខាងក្រៅ»។

កុមារា វ៉ាន់ សៀវហ្មុង មកពីព្រះសហគមន៍ពោធិ៍ធំ-ក្តីកណ្តាល បាននិយាយថា៖ «មិត្តសម្លាញ់ជីវិត ធ្វើឱ្យគាត់ទទួលបានចំណេះ(យល់)ដឹងច្បាស់ពីខ្លួនឯង និងអ្នកនៅជុំវិញ មិនតែប៉ុណ្ណោះ គាត់អាចយល់ពីបរិស្ថាន និងសង្គមខាងក្រៅ។

កុមារា សៀវហ្មុង បានបន្ថែមថា៖ «បើយើងគ្មានមិត្តក្នុងជីវិតទេ យើងក៏ពិបាកដើរតែម្នាក់ឯងបាន។ យើងរស់នៅចាំបាច់ត្រូវស្គាល់មិត្តភក្តិបងប្អូន និងមនុស្សដែលរស់នៅជុំវិញយើង»។

ចំណែក ជំទង់ ទូច ឌីណា សិស្សថ្នាក់ទី៨ខនៃវិទ្យាល័យដុនបូស្កូ បាននិយាយថា នាងចង់បានបទពិសោធទាក់ទងនឹងមិត្តនិងពីរបៀបរក្សាមិត្ត។

ក្រោយពីបានចូលរួមសិក្ខាសាលានេះ ឌីណា យល់ដឹងអំពីការរក្សាមិត្តភាព «ដោយចេះស្រឡាញ់ យោគយល់ លើកលែងទោសឱ្យគ្នា ចេះលើកទឹកចិត្តគ្នា និងផ្តល់ឱកាសឱ្យគ្នាទៅវិញទៅមក គឺដើម្បីឱ្យមិត្តភាពបានយូរអង្វែង»។

នាងបានប្រាបថា ៖ «ខ្ញុំចង់ផ្តាំទៅមិត្តរបស់ខ្ញុំថាខ្ញុំនៅតែស្រឡាញ់គាត់ មិនចង់ឱ្យបាត់បង់មិត្តណាទាំងអស់»។

បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបើកឱ្យមានដំណើរការនៃសកម្មភាពគ្រប់វិស័យឡើងវិញ ការិយាល័យយុវជន ជំទង់ កុមារ និងគ្រួសារក្នុងភូមិភាគភ្នំពេញ បានបង្កើតឱ្យមានកម្មវិធីសិក្ខាសាលាអំពី មិត្តសម្លាញ់ជីវិត នេះឡើងនៅតាមតំបន់មួយចំនួនក្នុងមណ្ឌលសកម្មភាពនានារបស់ព្រះសហគមន៍ក្នុងភូមិភាគភ្នំពេញ។

នេះជាសិក្ខាសាលាលើកទី២ហើយ ដោយលើកទី១ គឺធ្វើនៅជ្រៃធំ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី៨និង៩ ខែមករា ឆ្នាំ២០២២៕

# គ្រីស្តបរិស័ទរៃថវិកា សង់ផ្ទះ១ជូនស្ត្រីចំណាស់





*អត្ថបទ៖????*

លោក ផាន ប៉ូវ៉ា គ្រីស្តបរិស័ទបានសហការជាមួយមិត្តភក្តិរបស់លោក បានប្រមូលថវិកាផ្ទាល់ខ្លួនដើម្បីជួយសាងសង់ផ្ទះមួយខ្នងជូនស្ត្រីរស់នៅម្នាក់ឯងម្នាក់ឈ្មោះញ៉ឹក ស្រីវ៉ុន់ អាយុ៦៧ឆ្នាំ បន្ទាប់ពីត្រូវបានភ្លើងឆេះកាលពីថ្ងៃទី១៥ធ្នូ២០២១ កន្លងទៅ ដែលស្ថិតនៅភូមិកោះគល់ ឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

បើតាមឲ្យដឹងពីលោក ផាន ប៉ូវ៉ា បានឲ្យដឹងថា ដូនចាស់រូបនេះ គ្មានលទ្ធភាពសាងសង់ផ្ទះដោយខ្លួនឯងទេ ព្រោះសព្វថ្ងៃនេះ គាត់គ្មានការងារធ្វើ ហើយត្រូវពឹងលើអ្នកដទៃជួយជារឿយ។ លោកបន្តថា កន្លងមកដូនចាស់ជរារូបនេះក៏ត្រូវបានក្រុមរាំងសង់ដឺប៉ូល និងព្រះសហគមន៍កោះរកា ជួយជាស្បៀងអាហារ និងខោអាវជាញឹកញាប់ដល់រូបគាត់ផងដែរ។

ផ្ទះកំពុងសាងសង់ថ្មីនេះ មានទំហំ ៣x៣.៥០ ម៉ែត្រ សាងសង់ដោយដែកប្រក់ស័ង្កសី និងចំណាយទឹកប្រាក់អស់១.១៧០ដុល្លារ។ លោកប៉ូវ៉ាបានបញ្ជាក់ ប្រាក់ទាំងអស់នេះ បានមកពីការរៃអង្គាសពីកិច្ចការមនុស្សធម៌ ដូចជា ការជិះកង់ និងការប្រមែរប្រមូលដោយផ្ទាល់ខ្លួនជាមួយមិត្តភក្តិរបស់គាត់។

លោក ប៉ូវ៉ា បានឲ្យដឹងទៀតថា បន្ទាប់ពីត្រូវបានភ្លើងឆេះដូនចាស់រូបនេះបានទទួលជំនួយពីខាងរដ្ឋាភិបាល និង ចៅហ្វាយខេត្តកំពង់ចាម ដើម្បីចាត់ចែងចំណាយប្រចាំថ្ងៃរបស់គាត់។

លោកបានបន្ថែមថា កិច្ចការងារសម្រាប់អ្នកក្រីក្រ គឺជាតួនាទីរបស់គ្រីស្តបរិស័ទ «ជួបឬជួយអ្នកក្រីក្រម្តងស្មើនឹងជួបព្រះគ្រីស្តម្តង ព្រោះថាអ្នកក្រីក្រជារូបតំណាងឲ្យព្រះគ្រីស្ត ព្រោះថាពេលយើងទៅជួបអ្នកក្រីក្រយើងឃើញអ្វីពិសេសនៅក្នុងគាត់និងយើងមើលឃើញព្រះភ័ក្រព្រះយេស៊ូនៅក្នុងអ្នកក្រីក្រ»។

កិច្ចការនេះជាបេសកកម្មរបស់គ្រីស្តបរិស័ទដែលជាអ្នកដឹកនាំត្រូវជួយអ្នកក្រីក្រ និងផ្នែកមួយទៀត គឺគ្រីស្តបរិស័ទមានមុខងារជាព្យាការី គឺប្រកាសដំណឹងល្អទៅដល់សហគមន៍ផ្សេង។

គ្រីស្តបរិស័ទរូបនេះបានបញ្ជាក់ថា កន្លងទៅក្នុងឆ្នាំ២០២១ លោកបានផ្តល់ជាអណ្តូងទឹកស្អាតចំនួន០១គ្រួសារ តអគ្គិសនីជូនគ្រួសារក្រីក្រចំនួនមួយ ជួយធ្វើចង្ក្រានបាយឲ្យចាស់ជរាចំនួនមួយ និងជួយសាងសង់ផ្ទះចំនួន២ខ្នង ដែលខ្នងទីមួយមានទំហំ៣x៣.៣០ម៉ែត្រស្ថិតនៅ ភូមិអូឈ្លើង ឃុំកោះរការ ស្រុកកំពង់សៀម និងខ្នងទី២ទំហំ៣x៣ម៉ែត្រក្រាលការ៉ូ ស្ថិតនៅភូមិដូនធី ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម៕

# ការប្រកួតខ្លែងឯក ជាការបង្ហាញប្រាប់យុវជនខ្មែរ ឱ្យកាន់តែស្រឡាញ់វប្បធម៌ជាតិរបស់ខ្លួន



*អត្ថបទ៖ ផល សុផានិត*

ការប្រកួតបង្ហោះខ្លែងឯកលើកទី១១ ឆ្នាំ២០២២ បានប្រារព្ធធ្វើឡើងរយៈពេលពេញមួយថ្ងៃ នាថ្ងៃទី ០៨ ខែមករា ឆ្នាំ២០២២ នៅព្រះសហគមន៍កាតូលិក សន្តីម៉ារីញញឹម ស្ថិតនៅភូមិចំការទៀង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។

កម្មវិធីខាងលើធ្វើឡើងក្នុងន័យអបអរសាទរឆ្នាំថ្មី និងដើម្បីលើកស្ទួយកេរ្តិ៍ដំណែលមរតកវប្បធម៌ខ្មែរ ជាពិសេសការធ្វើខ្លែងឯក ដល់យុវវ័យជំនាន់ក្រោយ។

កម្មវិធីនេះប្រារព្ធឡើងក្រោមអធិបតីភាព លោកអភិបាល អូលីវីយ៉េ ហ្មិតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកប្រចាំភូមិភាគភ្នំពេញ លោក អ៊ឹង ណយ ប្រធានក្រុមប្រឹក្សាឃុំគុស និង លោក សៅ តុង អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តតាកែវ។

លោកអភិបាល អូលីវីយ៉េ ហ្មិតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកប្រចាំភូមិភាគភ្នំពេញ បានថ្លែងថា ៖«ការប្រកួតបង្ហោះខ្លែងក្នុងឆ្នាំនេះ យើងមានការចូលរួមច្រើន មកពីឃុំគូសទាំងមូល បានន័យថាមកពី៣០ភូមិ អាជ្ញាធរដែនដីផង មកពីវត្តផង មកពីចំការភ្នំវល្លិ៍ផង ដូច្នេះយើងមានកន្លែងផ្សេងៗដែលចូលរួម ហើយខ្ញុំសង្ឃឹមថាឆ្នាំក្រោយយើងនឹងអាចរៀបចំសម្រាប់ខេត្តតាកែវទាំងមូល»។

ថ្លែងនៅទីវាលប្រកួត លោកមាគ ស៊ិន ប្រធានមណ្ឌលសិប្បកម្មដូង ខេត្តតាកែវ និងជាប្រធានគណៈកម្មការបច្ចេកទេស រៀបចំការប្រកួតបង្ហោះខ្លែងឯកបានថ្លែងថា កម្មវិធីនេះ រៀបចំឡើងរយៈពេលពេញមួយថ្ងៃ ក្នុងគោលបំណងអបអរសាទរឆ្នាំថ្មី និងបណ្តុះស្មារតីស្រឡាញ់ ថែរក្សាប្រពៃណីវប្បធម៌របស់ខ្មែរ ទៅកាន់យុវជនជំនាន់ក្រោយ។

លោក សៅ តុង អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តតាកែវ បានលើកឡើងផងដែរថា ការបង្កើតខ្លែង មនុស្សគ្រប់គ្នាគិតថា ជាការកម្សាន្តសប្បាយ ក៏ប៉ុន្តែដូនតាបុព្វបុរសខ្មែរបានរកឃើញនូវអ្វីមួយ ក្រោយពីគាត់ប្រមូលភោគផលរួច គាត់ចេះច្នៃប្រឌិតនូវការធ្វើខ្លែងនេះ ហើយនេះក៏ជាការអបអរសាទរនូវសមិទ្ធផលរបស់គាត់ ដែលប្រមូលភោគផលបានកាលពីឆ្នាំកន្លងមកដែរ។

ជាមួយគ្នានេះដែរ លោកជុំ រដ្ឋា ជាកីឡាករប្រកួតបង្ហោះខ្លែងឯក មកពីភូមិថ្មកែវ ស្រុកត្រាំកក់ ខេត្តតាកែវ បានថ្លែងថា ការចូលរួមប្រកួតខ្លែងនេះ ដោយសារតែរូបលោក ចង់លើកស្ទួយនូវការធ្វើខ្លែងឯករបស់ខ្មែរកុំឱ្យបាត់បង់ និងចង់បង្ហាញការបង្ហោះខ្លែងដែលលោកធ្វើឡើង ទៅកាន់មហាជនដែលចូលរួមទស្សនា។





កីឡាករប្រកួតបង្ហោះខ្លែងឯកមួយរូបទៀត លោក ខាន់ ចេង មកពីភូមិត្រឡាក់ខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ បានថ្លែងឱ្យដឹងដែរថា៖ «ការប្រកួតខ្លែងនេះគឺចង់រក្សានូវប្រពៃណីខ្មែរយើងនេះ ដើម្បីឱ្យក្មេងៗជំនាន់ក្រោយ ចូលរួមថែរក្សាវប្បធម៌ខ្មែរយើង ជាពិសេសខ្លែងឯកនេះ ឱ្យបានគង់វង្ស»។

លោក ខាន់ ចេង បានបន្តថា ការប្រកួតខ្លែងជារឿងសំខាន់មួយ សម្រាប់អភិរក្សប្រពៃណី វប្បធម៌របស់ខ្មែរហើយក៏ជាការដាស់ពញ្ញាក់ស្មារតីកូនខ្មែរជំនាន់ក្រោយ ត្រូវចូលរួមថែរក្សានូវប្រពៃណីដ៏ចំណាស់មួយនេះ។

ខ្លែងឯក ដែលដាក់ចូលរួមប្រកួតក្នុងកម្មវិធីនានៅថ្ងៃទី ៨ ខែមករា មានចំនួនប្រមាណ ១២០ ដែលការរៀបចំប្រកួតនេះ មានវគ្គជម្រុះជ្រើសរើសតែលេខ ១ ដល់លេខ ។ អ្នកដែលទទួលបានលេខ ១ ទទួលបានទឹកប្រាក់ចំនួន ៦៥ ដុល្លារ ហើយខ្លែងដែលជាប់ចំណាត់ថ្នាក់លេខ០១នឹងត្រូវរក្សាទុកជាអនុស្សាវរីយ៍ផងដែរ។

ទន្ទឹមនឹងនោះដែរ ក្នុងពេលប្រកួងខ្លែងឯកសម្រាប់ឆ្នាំ ២០២២ នេះដែរ ក៏មានការរៀបចំសេះចំនួន១១ ក្បាល និងក្របីចំនួន ៦ ក្បាលក្នុងការដាក់ប្រណាំងក្នុងកម្មវិធីនេះផងដែរ៕

# ពិធីផ្ទេរមុខងារបូជាចារ្យថ្មី និងការថ្លែងអំណរគុណ ដល់បូជាចារ្យចាស់ នៅព្រះសហគមន៍ទំពូង





*អត្ថបទ៖ ព្រះសហគមន៍ភូមិភាគបាត់ដំបង*

នៅព្រឹកថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ ព្រះសហគមន៍កាតូលិកទំពូង ស្ថិតនៅក្នុងភូមិទំពូង ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង បានប្រារព្ធពិធីអភិបូជា បុណ្យគោរពព្រះនាងម៉ារីជាមាតារបស់ព្រះជាម្ចាស់ ដែលជាឧបការិនីរបស់ព្រះសហគមន៍ទំពូង(ខួប២៩ឆ្នាំ)។

នាឱកាសនោះ ក៏មានការរៀបចំពិធីថ្លែងអំណរគុណដល់លោកបូជាចារ្យសិលា ទម្លាប់ សុផល ដែលជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ទំពូង ដែលលោកបានធ្វើអស់រយៈពេល ២២ឆ្នាំកន្លងមក ដោយបានលោកបំពេញតួនាទី និងបំរើព្រះសហគមន៍ទំពូងអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត។

ស្របពេលជាមួយគ្នានោះដែរ លោកអភិបាលទេព ច័ន្ទ ពិសិដ្ឋ (គីគេ) ជាអភិបាលប្រចាំភូមិភាគបាត់ដំបង បានប្រកាសផ្ទេរមុខងារថ្មីដល់លោកបូជាចារ្យ ហ្វ្រង់ស៊ីស្លូ ជនជាតិបារាំង ឲ្យទទួលខុសត្រូវព្រះសហគមន៍ទំពូងផងដែរ។

លោកអភិបាលបានមានប្រសាសន៍ថា៖«លោកឪពុកសុផល បានជួយបងប្អូនគ្រីស្តបរិស័ទនៅព្រះសហគមន៍ទំពូងច្រើនណាស់ក្នុងណែនាំ ផ្តល់ជំនឿដល់បងប្អូន ហើយលោកពេលនេះមិនមានកម្លាំងខាងផ្លូវកាយច្រើន ប៉ុន្តែលោកមានកម្លាំងខាងផ្លូវវិញ្ញាណ លោកមានប្រាជ្ញាញាណ លោកជួយយើងបង្រៀនព្រះគម្ពីរ ឲ្យស្គាល់ពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់»។

លោកអភិបាលទេព ច័ន្ទ ពិសិដ្ឋ បានបន្ថែមថា ៖ «សូមបងប្អូនជួយ អធិដ្ឋានជូនលោកឪពុកសុផល ឲ្យគាត់មានកម្លាំង សុខភាពល្អ ដើម្បីបន្តកសាងព្រះសហគមន៍តទៅមុខទៀត»។

ចំណែក លោកបូជាចារ្យ ហ្វ្រង់ស៊ីស្លូ ក៏បានលើកឡើងនាឱកាសនោះផងដែរថា ៖ «ខ្ញុំសូមអរគុណលោកអភិបាលដែលបានទទួលខ្ញុំក្នុងភូមិភាគបាត់ដំបង និងឲ្យខ្ញុំបំរើព្រះសហគមន៍ទំពូងនេះ»។

លោកបានបន្តថា សម្រាប់លោកថ្ងៃនេះ គឺជាលើកទីមួយក្នុងជីវិត ដែលលោកជាបូជាចារ្យបានទទួលខុសត្រូវព្រះសហគមន៍មួយដ៏ពិតប្រាកដ ដើម្បីពង្រឹងជំនឿគ្រីស្តបរិស័ទក្នុងព្រះសហគមន៍ និងដឹកនាំគ្រីស្តបរិស័ទ ប្រៀបដូចគង្វាលដឹកនាំកូនចៀម និងដឹកនាំគេដើម្បីទៅដល់ស្ថានបរមសុខរួមជាមួយព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ៕









# រដ្ឋមន្ត្រីក្រសួងបរិស្ថាន ទស្សនកិច្ចព្រះសហគមន៍កាតូលិក ខេត្តព្រះសីហនុ

*អត្ថបទ៖ ដាលីស*

«សង្គមកម្ពុជា ជាសង្គមមួយដែលសាសនាណាក៏អាចលូតលាស់បាន និងទទួលយកបានគ្រប់ជាតិសាសនា ដែលយើងអាចនិយាយបានថានៅលើពិភពលោកមិនមានច្រើនទេ»។ នេះជាការថ្លែងឡើងរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន លោក សាយ សំអាល់ ក្នុងពេលលោកចុះជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំព្រះវិហារសន្តមីកាអែល ក្រុងព្រះសីហនុ នាថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២កន្លងមកនេះ។



ក្នុងឱកាសនោះ លោក សាយ សំអាល់ បានបញ្ជាក់ឱ្យដឹងថា កម្ពុជាមានសង្គមមួយដែលមានពហុវប្បធម៌ ប្រជាពលរដ្ឋគ្រប់រូប មានសិទ្ធិសេរីភាពពេញលេញ ក្នុងការគោរពប្រណិបត៍សាសនា ទៅតាមជំនឿរៀងៗខ្លួន។

លោកមានប្រសាសន៍ថា ៖ «ការគោរពព្រះជារឿងសំខាន់ មិនថាសាសនាណាក៏ដោយ ព្រោះព្រះនៅក្នុងសាសនា គឺអប់រំមនុស្សឱ្យសាងអំពើល្អ គិតល្អ និងជាពន្លឺបំភ្លឺជីវិតដល់អ្នកមានជំនឿ។ សាសនាក៏មានតួនាទីសំខាន់ក្នុងការកែប្រែ ឬផ្លាស់ប្តូរផ្នត់គំនិតរបស់មនុស្សឆ្ពោះទៅកាន់ផ្លូវត្រូវក្នុងខ្សែជីវិតរបស់ខ្លួនផងដែរ»។





ដំណើរទស្សនកិច្ចនេះ ត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅពីលោកបូជាចារ្យ យ៉ូហានអ៊ុន សុន ប្រធានព្រះសហគមន៍មណ្ឌលសកម្មភាពកំពង់សោម រួមនឹងលោក គឹម រតនា នាយកប្រតិបត្តិអង្គការការីតាសកម្ពុជាផងដែរ។

លោកបូជាចារ្យ យ៉ូហាន អ៊ុន សុន បានប្រាប់ឱ្យដឹងថា នៅក្នុងជំនួបនេះមានការចែករំលែកនូវជំនឿ និងសេចក្តីស្រឡាញ់ ដើម្បីឲ្យគ្រប់គ្នាចេះទទួលនិងស្រឡាញ់គ្នាទៅវិញទៅមក ដើម្បីធ្វើកិច្ចការរួមជាមួយគ្នាក្នុងសង្គមកម្ពុជា។

លោកបូជាចារ្យបានមានប្រសាសន៍ថា៖ «ក្នុងជំនួបនេះ ឯកឧត្តម សាយ សំអាល់ បានបើកចិត្តចូលរួមជាមួយព្រះសហគមន៍ដោយចិត្តទុកដាក់គោរពគ្នាទៅវិញទៅមក និងលើកស្ទួយចំពោះកិច្ចការមេត្តាករុណា និងកិច្ចការរបស់ព្រះសហគមន៍កាតូលិកនៅកម្ពុជា»។

លោកបានបន្ថែមថា តាមរយៈអង្គការការីតាសកម្ពុជា រដ្ឋមន្ត្រីរូបនេះបានឈ្វេងយល់និងសិក្សាពីព្រះសហគមន៍ និងរួមជាមួយរាជរដ្ឋាភិបាលដើម្បីកសាងសង្គមកម្ពុជា។

កន្លងមក ព្រះសហគមន៍កាតូលិកនៅកម្ពុជា ក៏ដូចជាអង្គការការីតាសកម្ពុជា បានធ្វើកិច្ចការមនុស្សធម៌ជាច្រើនសម្រាប់ប្រជាជនក្នុងមូលដ្ឋាន ក្នុងរាជធានីខេត្តចំនួន២៥ ដោយមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធនានា និងមន្ត្រីមូលដ្ឋានក្នុងគោលដៅ ជួយដល់ប្រជាជនក្រីក្រក្នុងតំបន់ឲ្យមានជីវភាពសមរម្យ ក្នុងនោះរួមមាន វិស័យអប់រំ បរិស្ថាន សេដ្ឋកិច្ចសង្គមកិច្ច និងកសិកម្មជាដើម។

លោកបូជាចារ្យ យ៉ូហានអ៊ុន សុន បានបញ្ជាក់ឲ្យដឹងថា កាលពីប៉ុន្មានឆ្នាំមុននេះ តាមរយៈលោករដ្ឋមន្ត្រី ព្រះសហគមន៍កាតូលិក ក៏បានទទួលសិទ្ធិគ្រប់គ្រង អភិវឌ្ឍ និងថែរក្សានូវព្រះវិហារចំណាស់មួយនៅលើភ្នំបូកគោ ពីខាងរាជរដ្ឋាភិបាលផងដែរ៕





# សិស្ស៣៧នាក់ នៃវិទ្យាល័យសន្តហ្វ្រង់ស្វ័រ ខេត្តតាកែវ បានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទាំងអស់

*អត្ថបទ៖ ដាលីស*

សិស្សនៃវិទ្យាល័យចំណេះទូទៅសន្តហ្វ្រង់ស្វ័រក្នុងខេត្តតាកែវ បានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឬបាក់ឌុប ១០០% ដោយក្នុងនោះក៏ទទួលបាននិទ្ទេសA ផងដែរ សម្រាប់លទ្ធផលនៃសម័យប្រលងកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ កន្លងមកនេះ។

អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លោក អូលីវីយ៉េ ឆ្មីតហាស្លេរ ដែលជាស្ថាបនិកវិទ្យាល័យចំណេះទូទៅសន្តហ្វ្រង់ស័រនេះ បានឱ្យដឹងតាមរយៈសាររបស់លោកកាលពីថ្ងៃទី១៥ ខែមករា ថា លទ្ធផលនៃការប្រលងបាក់ឌុបឆ្នាំ២០២១ សិស្សវិទ្យាល័យចំណេះទូទៅសន្តហ្វ្រង់ស្វ័រចំនួន ៣៧នាក់ បានប្រលងជាប់ទាំងអស់ ហើយក្នុងនោះមានបេក្ខជនចំនួន៩នាក់ទទួលបាននិទ្ទេស Aផងដែរ។

លោកអូលីវីយ៉េ បានលើកឡើងទៀតថា ទោះបីជាកម្ពុជាស្ថិតក្នុងស្ថានភាពនៃការរាតត្បាតវីរុសកូវីដ១៩ក៏ដោយ ក៏ការសិក្សាតាមរយៈប្រព័ន្ធអនឡាញ ស្ទើរតែពេញមួយឆ្នាំសិក្សាក៏ដំណើរការសិក្សាប្រព្រឹត្តិទៅឡើងបានយ៉ាងល្អប្រសើរដែរ។

ជាមួយគ្នានេះដែរ លោកអភិបាល អូលីវីយ៉េ ក៏បានអបអរសាទរចំពោះនាយកសាលា លោកគ្រូ អ្នកគ្រូ និងបុគ្គលិកទាំងអស់សម្រាប់ការប្តេជ្ញាចិត្ត និងភាពឧស្សាហ៍ព្យាយាម និងភាពក្លាហានចំពោះសិស្សានុសិស្សទាំងអស់ សម្រាប់ការខិតខំប្រឹងប្រែងរបស់ពួកគាត់។

លោកបានថ្លែងឱ្យដឹងថា៖ «សូមព្រះជាម្ចាស់ប្រទានពរ! មហាអបអរសាទរ លទ្ធផលដ៏អស្ចារ្យនេះ»។

ស្ថាបនិកវិទ្យាល័យសន្តហ្វ្រង់ស្វ័រដដែលរូបនេះបានបញ្ជាក់ឱ្យដឹងថា ក្នុងចំណោមបេក្ខជន ៣៧នាក់ដែលបានប្រលងជាប់នេះ មានអ្នកទទួលបាននិទ្ទេស A ចំនួន៩នាក់ និទ្ទេសB ចំនួន៦នាក់ និទ្ទេសC ចំនួន១៩នាក់ និងនិទ្ទេសD ចំនួន៣នាក់។

លោក ពេជ្រ វិបុល នាយកវិទ្យាល័យចំណេះទូទៅសន្តហ្វ្រង់ស្វ័រ ក៏បានប្រាប់ឱ្យដឹងដែរថា ក្នុងនាមជាគណៈគ្រប់គ្រងសាលា រួមជាមួយលោកគ្រូអ្នកគ្រូទាំងអស់ នៅពេលដែលទទួលបានដំណឹងថាសិស្សទទួលបានលទ្ធផលល្អ ពិតជាមានសេចក្តីសប្បាយរីករាយ និងមានមោទកភាពដែលទទួលបានលទ្ធផលនេះ។

លោកមានប្រសាសន៍ថា៖ «លទ្ធផលនេះជាការឆ្លើយតបនូវអ្វីដែលពួកយើងបានខិតខំប្រឹងប្រែងគ្រប់គ្នា។ ទោះបីជាស្ថិតក្នុងបរិបទកូវីដ-១៩ ក៏បេក្ខជនដែលជាសិស្សមកពីវិទ្យាល័យចំណេះទូទៅសន្តហ្វ្រង់ស្វ័រនៅតែទទួលបានចំណាត់ថ្នាក់ល្អ ដោយមាននិទ្ទេសAរហូតដល់២៤.៣៣%»។




ជាមួយគ្នានេះដែរ លោក ពេជ្រ វិបុល ក៏បានបញ្ជាក់ដែរថា ការរៀនតាមអនឡាញ ទោះបីជាមិនបានជួបផ្ទាល់ក៏ដោយ ប៉ុន្តែគ្រូមួយចំនួនធំមានសមត្ថភាពប្រើបច្ចេកវិទ្យា និងមានពេលដាក់កិច្ចការដែលអាចឱ្យសិស្សគ្រប់រូបអាចធ្វើបានរាល់ថ្ងៃ និងផ្ញើត្រលប់មកគ្រូវិញ។ ការធ្វើបែបនេះគឺធ្វើឱ្យគ្រូខិតខំធ្វើការលើសមុនគុណនឹងបី ខុសពីនៅក្នុងថ្នាក់ដែលមានតែសិស្សមួយឬពីរនាក់ឡើងមកធ្វើលំហាត់ដើម្បីកែបូកសរុបរួម។

លោក ពេជ្រ វិបុល ក៏បានផ្តាំផ្ញើដល់សិស្សដែលនឹងត្រៀមប្រឡងនៅឆ្នាំក្រោយ សូមមើលនិងយកគំរូតាមសិស្សច្បង ដោយខិតខំសិក្សាឈ្វេងយល់ដើម្បីទទួលបទពិសោធន៍បន្ថែម ដើម្បីអនាគតរបស់ខ្លួន។

បេក្ខជនដែលទទួលបាននិទ្ទេស A លោក ធីម ពេជ្រ បានប្រាប់ឱ្យដឹងថា ការប្រឡងនៅឆ្នាំនេះធ្វើដោយរលូនគ្មានភាពរអាក់រអួល និងសប្បាយចិត្តដែលសិស្សអាចប្រឡងឡើងវិញបាន ដោយខុសពីសិស្សឆ្នាំមុន។

លោកថា៖ «ខ្ញុំសប្បាយចិត្តដែលបានធ្វើដោយសមត្ថភាព និងមានកត្តា៣ដែលជួយជំរុញខ្ញុំឱ្យទទួលបាននិទ្ទេស A នេះ គឺខ្លួនឯង គ្រួសារ និងសង្គម»។

យុវសិស្ស ធីម ពេជ្រ បានបញ្ជាក់ទៀតថា៖ «កាលដើមឆ្នាំខ្ញុំមិនសូវបានខិតខំព្រោះគិតថាសម័យកូវីដនឹងជាប់ដោយស្វ័យប្រវត្តិដូចឆ្នាំមុន តែក្រោយពីទទួលបានដំណឹងថាមានការប្រឡង ខ្ញុំបានប្រឹងប្រែងរៀនជាងមុនមិនត្រឹមតែតាមកាលវិភាគប៉ុណ្ណោះទេ តែខ្ញុំត្រូវខិតខំបន្ថែមទៀតចំពោះមុខវិជ្ជាណាដែលខ្ញុំនៅស្ទើរ»។

ឪពុកម្តាយរបស់លោកលោក ធីម ពេជ្រ តែងតែជំរុញ និងលើកទឹកចិត្តឱ្យរៀនដោយមានទាំងសម្ភារៈសិក្សាផងដែរ។ នេះបើតាមការលើកឡើងបន្ថែមពីយុវជនរូបនេះ ដោយលោកបានបន្តថា ចំពោះកត្តាសង្គម គឺការបើកឱ្យមានការរៀនតាមអនឡាញនិងរៀបចំតឹងរឹងក្នុងការប្រឡងដែលធ្វើឱ្យលោកមានជំនឿចិត្តក្នុងប្រលងនេះ។

លោក ធីម ពេជ្រ បាននិយាយថា ៖ «ក្រោយពីទទួលបានលទ្ធផលនេះ ខ្ញុំពេញចិត្តនឹងចូលរៀនផ្នែកមេកានិច និងវិស្វករ ហើយក៏ធ្លាប់បានដាក់ពាក្យអាហាររូបករណ៍នៅសាលាតិចណូដែលជាសាលាដែលខ្ញុំចង់រៀន»។

យោងតាមសេចក្តីប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានចេញផ្សាយនាថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ បានឱ្យដឹងថា បេក្ខជនដែលចូលរួមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានចំនួនសរុប ១១៤ ១៨៧ នាក់ ទូទាំងប្រទេស។

បេក្ខជនដែលបានប្រឡងជាប់មានចំនួន ៧២ ០១៦នាក់ ស្មើនឹង ៦៥.៦៥% ក្នុងនោះមានបេក្ខជនដែលទទួលបាននិទ្ទេស A ទូទាំងប្រទេស មានចំនួន ១ ៧៥៣ នាក់៕

# យុវសិស្ស៨នាក់នៃវិទ្យាល័យចម្រើនវិជ្ជាទទួលនិទ្ទេសA

*អត្ថបទ៖ ហៀម សុកខុន*

«សប្បាយចិត្តជាខ្លាំង ហើយមិត្តភក្តិរួមទាំងលោកគ្រូអ្នកគ្រូវិញចូលរួមអបអរ ព្រោះការរំពឹងទុកពិតជាទទួលបានមែន»។ នេះជាសម្តីរបស់យុវសិស្សទទួលបាននិទ្ទេសA ក្នុងការប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០២១ នៃវិទ្យាល័យចម្រើនវិជ្ជា ក្នុងខេត្តព្រៃវែង ឈ្មោះចាន់ គីមឡុង។

លោក ចាន់ គីមឡុង បានឲ្យដឹងថា ប្រព័ន្ធអប់រំនៅវិទ្យាល័យចម្រើនវិជ្ជា គឺល្អខ្លាំងជាងសាលាដែលគាត់ធ្លាប់រៀនកន្លងមកទាំងការអប់រំចំណេះដឹង និងការអប់រំចរិយាមាយាទ។ គីមឡុងបន្ថែមថា រយៈពេល៣ឆ្នាំដែលគាត់បានរៀននៅក្នុងសាលានេះ គាត់ទទួលបានការយកចិត្តទុកដាក់ពីសំណាក់លោកគ្រូអ្នកគ្រូនិងគណៈគ្រប់គ្រងសាលាដូចជាផ្ទះរបស់ខ្លួន។

យុវតី អ៊ុង អនណានីតា ដែលបានប្រឡងជាប់និទ្ទេសAដែរនោះ បានឲ្យដឹងថា វិទ្យាល័យចម្រើនវិជ្ជា ជាសាលារៀនមួយដែលធ្វើឲ្យនាងទទួលបានចំណេះ និងបទពិសោធច្រើន មិនថាជីវិតនៅក្នុងថ្នាក់ក៏ដូចជាជីវិតរស់នៅប្រចាំថ្ងៃ។

អនណានីតា និយាយថា «ចេះចែករំលែកចំណេះដឹងឲ្យគ្នា រួមការងារជាមួយលោកគ្រូអ្នកគ្រូ និងមានភាពស្និទ្ធស្នាលខ្លាំងដែលខុសប្លែកពីសាលាដែលធ្លាប់រៀននៅអនុវិទ្យាល័យ»។

យុវតី អនណានីតា និយាយដោយរំភើបចិត្តចំពោះនិទ្ទេសដែលនាងបានទទួលថា នាងសប្បាយចិត្តខ្លាំង ព្រោះថាអ្នកណាៗក៏ចង់បាននិទ្ទេសAដែរ ហើយការទទួលបាននេះ មិនបានមកពីការចម្លងនោះឡើយ គឺបានមកពីសមត្ថភាព។

វិទ្យាល័យចម្រើនវិជ្ជា ជាសាលារបស់ព្រះសហគមន៍កាតូលិកបង្កើតឡើង ដើម្បីពង្រឹងវិស័យអប់រំក្នុងខេត្តព្រៃវែង ឲ្យកាន់តែមានសន្ទុះកើនឡើង ជាពិសេសគឺបណ្តុះបណ្តាលយុវសិស្សឲ្យទទួលបានចំណេះដឹងមួយពិតប្រាកដ និងឲ្យពួកគេក្លាយជាធនធានមួយសំខាន់សម្រាប់សង្គមជាតិ។ វិទ្យាល័យនេះ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៨ ដែលមានថ្នាក់ទី១០មួយបន្ទប់ ថ្នាក់ទី១១ មួយបន្ទប់ និងថ្នាក់ទី១២មួយបន្ទប់ សរុបមានសិស្សបច្ចុប្បន្នចំនួន១៣៥នាក់។ សិស្សបញ្ចប់ការសិក្សាសរុបមាន១២ជំនាន់ ដែលមានមានសិស្សចំនួន ៥៤០នាក់។

ក្នុងឆ្នាំប្រលង២០២១-២០២២នេះ វិទ្យាល័យចម្រើនវិជ្ជាមានសិស្សប្រលងមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) មានចំនួន៤៥នាក់ លទ្ធផល មាននិទ្ទេសA ចំនួន៨នាក់ និទ្ទេសB ១០នាក់ និទ្ទេសC ១៦នាក់ និទ្ទេសD ៣៣នាក់ និងធ្លាក់ចំនួន០១នាក់។

ដូនជី អាង សង្វាត ក្រុមប្រឹក្សាយោបល់នៃវិទ្យាល័យចម្រើនវិជ្ជា បានសម្តែងនូវអារម្មណ៍រីករាយជាខ្លាំងដែលយុវសិស្សនៅវិទ្យាល័យចម្រើនវិជ្ជា ទទួលបាននិទ្ទេសល្អជាប់ៗគ្នា ច្រើនឆ្នាំកន្លងមកនេះ។

ដូនជីនៃក្រុមប្រឹក្សាយោបល់រូបនេះបានបញ្ជាក់ថា ៖ «បើទោះបីមានកូវីដ-១៩ ក៏សិស្សានុសិស្សទាំងអស់យកចិត្តទុកដាក់រៀនតាម



អនឡាញ ទោះកន្លែងខ្លះពិបាកប្រើអ៊ីនធឺណិតក៏ដោយ។ អ្នកគ្មានអ៊ីនធឺណិត តម្រូវឲ្យមកសាលាដើម្បីទទួលបានសេវាអ៊ីនធឺណិត»។

ដូនជី អាង សង្វាត បានលើកឡើងថា សាលាបានជួយសិស្សក្រីក្រជាច្រើននាក់ ដើម្បីទទួលបានការអប់រំ និងរៀនសូត្រ គោរពតាមវិន័យសាលា និងចូលរួមសកម្មភាពផ្សេងៗយ៉ាងសកម្មនៅក្នុងសង្គម។

បច្ចុប្បន្នវិទ្យាល័យចម្រើនវិជ្ជាមាន៤សាខា ដែលសាខាទីមួយចាប់ផ្តើមកាលពីឆ្នាំ២០០៨ ក្នុងខេត្តព្រៃវែង ទី២ អនុវិទ្យាល័យចម្រើនវិជ្ជានៅផ្កាដូង ខេត្តកំពង់ចាម សាខាទី៣ វិទ្យាល័យចម្រើនវិជ្ជា នៅថ្មពេជ្រ ក្នុងខេត្តត្បូងឃ្មុំ និងសាលាទី៤ ទើបតែចាប់ផ្តើមបើកក្នុងឆ្នាំ២០២២នេះ គឺវិទ្យាល័យចម្រើនវិជ្ជា នៅក្រុងកំពង់ចាម ខេត្តកំពង់ចាម៕

# វគ្គបណ្តុះបណ្តាលខ្លីដល់គ្រូមត្តេយ្យនៃព្រះហាគមន៍ កាតូលិកចំនួន៧នាក់ បានបញ្ចប់ដោយជោគជ័យ

*អត្ថបទ៖ ចេង ជំនិត*

វគ្គបណ្តុះបណ្តាលរយៈពេលជិតមួយខែ ស្តីពីគរុកោសល្យមត្តេយ្យសិក្សា ដែលរៀបចំឡើងដោយ «គម្រោង ECRC នៃសមាគមគ្រួសារយើង» ដល់គ្រូមត្តេយ្យនៃព្រះហាគមន៍កាតូលិកចំនួន៧នាក់ ត្រូវបានបញ្ចប់ដោយជោគជ័យ។

វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តិទៀងកាលពីថ្ងៃ០៣ ដល់ទី២៧ ខែមករា ឆ្នាំ២០២២ ដែលតាមរយៈវគ្គបណ្តុះបណ្តាលនេះ គ្រូមត្តេយ្យទាំងនេះអាចអភិវឌ្ឍចំណេះដឹងថ្មីៗចំនួន១៤ប្រធានបទ ព្រមទាំងបានសិក្សាចំណេះដឹងថ្មីៗជាច្រើនពីសិក្ខាកាមផ្សេងៗ និងអ្នកជំនាញជាច្រើននាក់មកពីគម្រោងមជ្ឈមណ្ឌលធនធានកុមារតូចនៃសមាគមគ្រួសារយើង រួមនឹងនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ក៏ដូចជានាយកដ្ឋានអប់រំសុខភាព និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម។

បងស្រីអាង សង្វាត ជាដូនជីមកពីព្រះសហគមន៍កាតូលិកខេត្តព្រៃវែងបាននិយាយថា ៖ «មូលហេតុដែលព្រះសហគមន៍បញ្ជូនគ្រូៗសាលាមត្តេយ្យមកទទួលការអប់រំវគ្គបណ្តុះបណ្តាលនៅសមាគមគ្រួសារយើង ព្រោះសមាគមគ្រួសារយើងមានការយកចិត្តទុកដាក់ខ្ពស់ក្នុងការបណ្តុះបណ្តាលគរុកោសល្យមត្តេយ្យសិក្សាប្រកបដោយគុណភាព»។

ជាក់ស្តែង វគ្គបណ្តុះបណ្តាលនេះមានគោលបំណងពង្រឹងចំណេះដឹងរបស់លោកគ្រូមត្តេយ្យទាំង៧រូប លើការអភិវឌ្ឍន៍កុមារតូចគរុកោសល្យមត្តេយ្យសិក្សា និងកម្មវិធីសិក្សារបស់ថ្នាក់មត្តេយ្យ ព្រមទាំងវិធីសាស្ត្រក្នុងការបង្រៀន ការគ្រប់គ្រងថ្នាក់រៀន ក៏ដូចជារបៀបទំនាក់ទំនង











ជាមួយគណៈកម្មាធិការសាលា និងឪពុកម្តាយរបស់កុមារជាដើម។

បេក្ខជនទាំងអស់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលលើកទី១នេះបានប្រកបដោយជោគជ័យ បន្ទាប់ពីខិតខំប្រឹងប្រែងទទួលការបណ្តុះបណ្តាលយ៉ាងយកចិត្តទុកដាក់អស់រយៈពេល២២ថ្ងៃ។

# លោក វ៉ារី សុភារ៉ុង៖ «ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំ ឲ្យបង្ហាញជំនឿទៅបងប្អូន តាមរយៈរបាំប្រពៃណីខ្មែរ»



*អត្ថបទ៖ ឆាក លាំង*

ជាគ្រូបង្រៀនរបាំបុរាណខ្មែរមួយរូប នៅព្រះសហគមន៍ផ្សារតូច លោក វ៉ារី សុភារ៉ុង ជាគ្រីស្តបរិស័ទ មានវ័យ២៥ឆ្នាំ ក្នុងគ្រួសារដែលបងប្អូនប្រុសស្រីចំនួន២នាក់ មានម្តាយជាគ្រីស្តបរិស័ទ និងឪពុកជាពុទ្ធបរិស័ទ។

ដោយសារតែគ្រួសារខាងម្តាយមានជំនឿលើព្រះយេស៊ូគ្រីស្ត លោកបានស្គាល់និងចូលព្រះវិហារតាំងពីវ័យក្មេងជាមួយលោកយាយ។ ស្របពេលមិនមានការជំទាស់ពីឪពុកជាពុទ្ធបរិស័ទ លោកសុភារ៉ុងក៏បានចូលរៀនស្វែងយល់ជំនឿលើសាសនាព្រះគ្រីស្តនិកាយកាតូលិក ជាមួយលោកអ្នកអ្នកគ្រូនិងទទួលពិធីជ្រមុជទឹក នៅព្រះសហគមន៍ផ្សារតូច មណ្ឌលសកម្មភាពភ្នំពេញខាងជើង នាភូមិភាគភ្នំពេញ។

លោក វ៉ារី សុភារ៉ុង សព្វថ្ងៃកំពុងតែធ្វើការងារនៅក្រុមហ៊ុនសាងសង់មួយកន្លែងក្នុងទីក្រុងភ្នំពេញ។ ដោយសារតែការស្រលាញ់ លោកក៏ឆ្លៀតពេលវេលាជួយបង្ហាត់បង្រៀនក្មេងៗ ពីរបាំបុរាណខ្មែរនៅព្រះសហគមន៍ផ្សារតូច។

ក្នុងជីវិតជាគ្រីស្តបរិស័ទជាច្រើនឆ្នាំមកនេះ លោកបានទទួលបទពិសោធក្នុងជីវិតប្រចាំថ្ងៃ និងភាពអស្ចារ្យពីព្រះជាម្ចាស់ពិតមែន។

គ្រីស្តបរិស័ទរូបនេះបាននិយាយថា៖ «ពេលមួយដែលខ្ញុំពិបាកចិត្តខ្លាំងរឿងការសិក្សា ក្នុងក្រុមគ្រួសារ និងមានជំលោះជាមួយមិត្តភ័ក្ក ខ្ញុំបានទៅព្រះវិហារតែម្នាក់ឯង ដើម្បីអធិដ្ឋានថ្វាយគ្រប់ការលំបាក់ ទុក្ខសោកទាំងអស់ទៅទ្រង់ ពេលនោះស្រាប់តែខ្ញុំបាននឹកឃើញអត្ថបទគម្ពីរមួយដែលនិយាយថា ខ្ញុំនឹងឲ្យអ្នកសម្រាក»។

លោកបានបន្តទៀតថា ៖ «ក្រោយពីគិតពីព្រះបន្ទូលមួយឃ្លានេះមួយសន្ទុះក្រោយ ខ្ញុំមានអារម្មណ៍ថាធូរស្រាលក្នុងចិត្ត។ ចាប់តាំងពីថ្ងៃនោះមក ខ្ញុំដឹងថា រាល់ការអធិដ្ឋានទៅទ្រង់គឺយើងនឹងទទួលការឆ្លើយតបពីព្រះអង្គពិតមែន»។

ជាយុវជនមួយរូបដែលជាអតីតសិស្សរបស់ការិយល័យសិល្បៈនៃព្រះសហគមន៍ គ្រីស្តបរិស័ទវ័យក្មេង សុភារ៉ុង បានដាក់អារម្មណ៍ចូលរួម និងថែរក្សាវប្បធម៌ខ្មែរផ្នែករបាំ ដោយបានផ្តល់ចំណេះដឹងជួយបង្ហាត់បង្រៀនក្មេងទូទៅ ដែលចាប់អារម្មណ៍ពីរបាំបុរាណខ្មែរ ទោះត្រូវចំណាយពេលច្រើនក្នុងការបង្រៀនក៏ដោយ។

លោកបានបន្ថែមថា៖ «ទម្រាំតែចេះរាំ និងអាចផ្ទេរចំណេះដឹងនេះ ទៅប្អូនៗដូចពេលនេះបាន ខ្ញុំ ហែលឆ្លងពាក្យមើលងាយ សើចចំអកការពេបជ្រាយពីមនុស្សជុំវិញខ្លួនរាប់មិនអស់។ អ្នកខ្លះថាមនុស្សប្រុសបែរជារៀនរបាំ? ខ្លះទៀតថាខ្ញុំខ្ទើយ តែដោយសារព្រះជាម្ចាស់គង់ជាមួយ និងទឹកចិត្តស្រលាញ់ ខ្ញុំក៏ធ្វើបានដូចពេលនេះ»។

កំពុងតែបង្ហាញពីក្បាច់រាំ ដ៏ទន់ល្វត់ល្វន់ឲ្យសិស្សៗមើល គ្រីស្តបរិស័ទរូបនេះបានបន្តនិយាយទៀតថា ក្នុងនាមលោកជាកូនខ្មែរ និងជាគ្រីស្តបរិស័ទខ្មែរមួយរូប លោកចង់ចូលរួមថែរក្សាវប្បធម៌ដ៏ផូរផង់នេះ។

លោកថា ៖ «ខ្ញុំព្យាយាមបង្ហាញជំនឿរបស់ខ្ញុំតាមរយៈការសម្តែងរបាំឬការបង្ហាត់របាំនេះ ឲ្យបងប្អូនដែលមានជំនឿផ្សេង បានស្គាល់អំពីសាសនា និងជំនឿដែលខ្ញុំកំពុងតែប្រតិបត្តិសព្វថ្ងៃនេះ»។

ជាធនធានមនុស្សមួយរូបរបស់ព្រះសហគមន៍ លោក សុភារ៉ុង បានបង្ហាញពីការតាំងចិត្តនិងការព្យាយាមរបស់ខ្លួនថា ៖ «បច្ចុប្បន្នភាពលោកបានខិតខំផ្សារភ្ជាប់ជាមួយព្រះជាម្ចាស់ដោយការចូលព្រះវិហារ ចូលរួមកិច្ចការមនុស្សធម៌របស់ព្រះសហគមន៍ ពិសេសគឺការអធិដ្ឋានជារៀងរាល់ថ្ងៃ»៕

# សកម្មភាពនានារបស់ព្រះសហគមន៍កាតូលិកកម្ពុជា

## ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង



## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ



## ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម

